00208198

D97

osseនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| ដាក់ទៅ: | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់: | ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28/07/2008
ម៉ោង (Time/Heure): 09:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA. FRY

---

**ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហឧក្រិដ្ឋកម្មរួម* (JCE)**

---

**អ្នកដាក់ឯកសារ៖**
សហមេធាវីរបស់លោក អៀង សារី
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**
សហចៅក្រមស៊ើបអង្កេត
លោក យូ ប៊ុនឡេង
លោក Marcel LEMONDE

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26/03/2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA. Fry

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28/07/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA. FRY

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26/03/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA. Fry

តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារ") តទៅនេះ លោក អៀង សារី អនុលោមតាមវិធាន ផ្ទៃក្នុង ៥៣.១ សូមចាប់ផ្តើមធ្វើការជំទាស់ការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវផ្នែក ព្រហ្មទណ្ឌ ដែលគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម("JCE") ។ សំណើនេះត្រូវតែធ្វើជាចំបាច់ ពីព្រោះ មានការលេចឮថា ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") កំពុងស្វះស្វែងយ៉ាងណាក់លៀមឱ្យ មានការអនុវត្តសហឧក្រិដ្ឋកម្មរួម JCE ដូចដែលបានបង្ហាញនៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ខ្លួន[1] ដែលក្នុងនោះសេចក្តីប្រកាសព័ត៌មានបានគូសបញ្ជាក់ថា បទល្មើសដែលបានចោទប្រកាន់នៅក្នុងដីកាសន្និ ដ្ឋានបញ្ជូនឱ្យស៊ើបសួរ ត្រូវបាន"ប្រព្រឹត្តឡើងជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម...[2]"។ សហឧក្រិដ្ឋកម្មរួម JCE ដាក់ការទទួលត្រូវផ្នែកព្រហ្មទណ្ឌនៅពេលមនុស្សពីរនាក់ ឬច្រើនជាងនេះ ដែលបានមានចំណែកនៅ ក្នុងផែនការឧក្រិដ្ឋកម្មរួមដែលបទល្មើសត្រូវបានប្រព្រឹត្តជាបច្ច័យនៃផែនការនោះ។ សមាជិកនានាដែលចូល រួមក្នុងផែនការឧក្រិដ្ឋកម្ម មិនត្រឹមតែត្រូវទទួលខុសត្រូវចំពោះបទល្មើសដែលពួកគេបានព្រមព្រៀងប្រព្រឹត្ត នោះទេ តែថែមទាំងរាល់បទល្មើសដទៃទៀតដែលអាចកើតចេញពីធម្មជាតិ និងផលវិបាកដែលអាចមើល ឃើញទុកជាមុនរបស់ផែនការ ដោយមិនគិតថាតើបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តដោយមនុស្សនៅខាង ក្រៅផែនការឧក្រិដ្ឋកម្មនោះឡើយ[3] ។ សហឧក្រិដ្ឋកម្មរួម JCE ដែលជាទម្រង់នៃការទទួលខុសត្រូវ ព្រហ្មទណ្ឌ មិនអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក បានទេ ពីព្រោះ (ក) វាមិនបានបញ្ញត្តិនៅ ក្នុងច្បាប់បង្កើត អ.វ.ត.ក (ខ) វាមិនមែនជាផ្នែកមួយនៃច្បាប់កម្ពុជា (គ) វាមិនត្រូវបានទទួល

---

[1] សូមមើលសេចក្តីប្រកាសព័ត៌មានពីសេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

[2] គោលគំនិតនៃសហឧក្រិដ្ឋកម្មរួម JCE អាចហៅខុសគ្នាៗ និង អាចផ្លាស់ប្តូរគ្នាបាន ដូចជា"ផែនការឧក្រិដ្ឋកម្មរួម" (common criminal plan) "គោលបំណងឧក្រិដ្ឋកម្មរួម" (common criminal purpose) "ផែនការរួម ឬ គោលបំណង រួម" (common design or purpose) "គោលបំណងឧក្រិដ្ឋកម្មរួម" (common criminal purpose) "គោលបំណងរួម" (common purpose) "ផែនការរួម" (common design) ឬ "ផែនការរួមដែលមានការព្រមព្រៀង" (common concerted design) ។ គោលបំណងរួមមានលក្ខណៈទូទៅច្រើនដែលត្រូវបានពិពណ៌នាដើម្បីបង្កើតទម្រង់នៃ "ការប្រព្រឹត្តឧក្រិដ្ឋកម្ម" (criminal enterprise) "ការប្រព្រឹត្តឧក្រិដ្ឋកម្មរួម" (common enterprise) និង "សហកម្មឧក្រិដ្ឋកម្មរួមគ្នា" (Join Criminal Enterprise) ។ សូមមើល *ករណីរដ្ឋអាជ្ញា តទល់ជាមួយ Brdanin & Talic*, IT-99-36-PT, សេចក្តីសម្រេច ស្តីពីទម្រង់នៃដីកាចោទប្រកាន់ដែលត្រូវបានកែប្រែបន្ថែម និង សេចក្តីស្នើរបស់រដ្ឋអាជ្ញាសុំការកែប្រែ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ២៤ ។

[3] សូមមើល*ករណីរដ្ឋអាជ្ញា តទល់ជាមួយ Haradinaj et al.*, IT-04-84 សាលក្រមចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ១៣៥ ។ "អង្គជំនុំជម្រះតុលាការកំពូលលើករណី *Tadić* យល់ឃើញយ៉ាងទូលំទូលាយថា មនុស្សម្នាក់ក្នុងការអនុវត្ត ផែនការឧក្រិដ្ឋកម្មរួមចូលរួមចំណែកការប្រព្រឹត្តឧក្រិដ្ឋកម្មដោយមនុស្សមួយក្រុម អាចទទួលខុសត្រូវព្រហ្មទណ្ឌដោយ គោរពទៅតាមលក្ខខណ្ឌជាក់លាក់តែប៉ុណ្ណោះ" ។

ស្គាល់ដោយច្បាប់ទំនៀមទំលាប់អន្តរជាតិ ហើយទោះបីវាជាត្រូវទទួលស្គាល់នាពេលបច្ចុប្បន្ន ក៏វាមិនមែនជាច្បាប់ទំនៀមទំលាប់អន្តរជាតិក្នុងរវាងឆ្នាំ១៩៧៥-៧៩ ដែរ ហើយវាក៏មិនមែនជាច្បាប់ទំនៀមទំលាប់អន្តរជាតិដែលអនុវត្តដោយផ្ទាល់ដោយតុលាការកម្ពុជាដែរ និង (ឃ) វាមិនត្រូវបានទទួលស្គាល់ដោយអនុសញ្ញាអន្តរជាតិដែលអាចអនុវត្តនៅ អ.វ.ត.ក ។ អាស្រ័យហេតុនេះ ការអនុវត្តន៍សហឧក្រិដ្ឋកម្មរួម (JCE) នៅ អ.វ.ត.ក នឹងរំលោភបំពាន *គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង* (*nullum crimen sine lege*) ។ តាមរយៈការស្វែងរកការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) នៅអង្គជំនុំជម្រះវិសាមញ្ញ ក.ស.ព កំពុងដាក់ការទទួលខុសជាស្រមោលត្រូវយ៉ាងធំទៅលើឥស្សរជនសំខាន់ៗរបស់កម្ពុជា និងអ្នកដទៃទៀត [លុបចេញ]

[លុបចេញ]

---

[លុបចេញ]

00២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

[លុបចេញ]

[លុបចេញ]

## I. ការវិវឌ្ឍន៍និងនិយមន័យនៃការទទួលខុសត្រូវបែបសហកម្មឧក្រិដ្ឋកម្មរួម JCE

1. សហឧក្រិដ្ឋកម្មរួម (JCE) គឺជាទ្រឹស្តីស្ថាបនាដោយតុលាការដែលត្រូវបានបង្កើតឡើងតាមរយៈការវិភាគដែលមិនទូលំទូលាយទៅលើរឿងក្តីដ៏មានកម្រិតក្រោយសង្គ្រាមលោកលើកទី២ និងអនុសញ្ញាអន្តរជាតិ[17] ដែលនាំឱ្យអង្គជំនុំតុលាការកំពូលរបស់តុលាការ ICTY នៅក្នុងរឿងក្តី *Tadić* ធ្វើសេចក្តីសន្និដ្ឋានដ៏ចំរូងចំរាស់[18] ថា សហឧក្រិដ្ឋកម្មរួម (JCE) "ត្រូវបានបង្កើតយ៉ាងរឹងមាំនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិ"[19]។ ក្នុងការយល់ឃើញដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បានសំរិតសំរាំងករណីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកទីII ដោយស្វែងរកករណីនានាដែលខ្លួនជឿជាក់ថា ទ្រឹស្តីនេះត្រូវបានគេអនុវត្ត[20] ។ សំខាន់ជាងនេះទៅទៀតអង្គជំនុំជម្រះតុលាការកំពូល បានសំអាងទៅលើអនុសញ្ញាអន្តរជាតិចំនួនពីរដែលមិនទាន់ចូលជាធរមាននៅឡើយក្នុងអំឡុងពេលពាក់ព័ន្ធ[21] ។ បើទោះបីជាចែងមិនច្បាស់នៅក្នុងច្បាប់លក្ខន្តិកៈ ICTY អង្គជំនុំជម្រះតុលាការកំពូលលើករណី *Tadić* បានរកឃើញថា សហឧក្រិដ្ឋកម្មរួម (JCE) គឺជាទម្រង់នៃ "ការប្រព្រឹត្តបទល្មើស"[22]។

---

[illegible]

[17] បញ្ហានេះត្រូវបានពិភាក្សាស៊ីជំរៅនៅផ្នែក III ខ ខាងក្រោម ។

[18] "ចាប់តាំងពីសាលដីការបស់ *Tadić* ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ សហកម្មឧក្រិដ្ឋកម្មរួម JCE ដែលជាទម្រង់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអន្តរជាតិ បានវិវឌ្ឍទៅជាធាតុផ្សំដ៏ចំរូងចំរាស់នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" Goran Sluiter, មានទោសដោយសារចងក្រងជាបក្សពួក (Guilt by Association)៖ សហកម្មឧក្រិដ្ឋកម្មរួមឡើងសវនាការ (Joint Criminal Enterprise on Trial) 5 J. INT'L CRIM, JUST. 67 (2007) ។

[19] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Tadić,* IT-94-1-A សាលដីកាចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ [ចាប់ពីពេលនេះតទៅហៅថាសាលដីកា *Tadić*] កថាខណ្ឌ២២០ ។

[20] ករណី*រដ្ឋអាជ្ញា តទល់ជាមួយ Brjanin,* IT-99-36-A សារណារបស់សមាគមនីមេធាវីការពារនៅ ICTY ចុះនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២00៥ កថាខណ្ឌ១៤ ។ សូមមើលសារណាខាងលើ កថាខណ្ឌទី១៥ ដល់ទី៣៨ សម្រាប់ការវិភាគលើករណីដែលអង្គជំនុំជម្រះតុលាការកំពូល *Tadić* បានសំអាង ។

[21] សាលដីកា *Tadić* កថាខណ្ឌ ២២១-២២ ។ ពិភាក្សាស៊ីជំរៅនៅកថាខណ្ឌទី១៨-២0 ខាងក្រោមនេះ ។

[22] ករណីយោងខាងលើ កថាខណ្ឌទី ១៨៧ ដល់ទី១៩៣ ។

2. JCE ដែលបច្ចុប្បន្ននេះអនុវត្តនៅតុលាការពិសេសចំពោះកិច្ច (ad hoc) មានបីទម្រង់ខុសៗគ្នា៖

ក. សហឧក្រិដ្ឋកម្មរួម (JCE) I (ទម្រង់មូលដ្ឋាន basic form) សំអាងលើហេតុផលនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលនៅពេល "សហចុងចោទទាំងអស់ប្រព្រឹត្ត [...] អនុលោមទៅតាមផែនការរួម [និង] មានចេតនាព្រហ្មទណ្ឌដូចគ្នា [...] បើទោះបីសហចារីនិមួយៗអនុវត្តតួនាទីខុសៗគ្នានៅក្នុង [សហកម្មឧក្រិដ្ឋកម្មរួម (JCE)][23] ក៏ដោយ ។

ខ. សហឧក្រិដ្ឋកម្មរួម (JCE) II (ទំរង់ជាប្រព័ន្ធ systemic form) "ត្រូវបានកំណត់ដោយអត្ថិភាពនៃប្រព័ន្ធឧក្រិដ្ឋកម្មដែលមានការរៀបចំ ជាពិសេសករណីជំរុំប្រមូលផ្តុំ ឬ ជំរុំឃុំឃាំង"[24]

គ. សហឧក្រិដ្ឋកម្មរួម (JCE) III (ទំរង់លាតសន្ធឹង extended form) សំអាងលើហេតុផលនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលនៅក្នុងស្ថានភាព "ពាក់ព័ន្ធជាមួយគោលបំណងឧក្រិដ្ឋរួមដើម្បីប្រព្រឹត្តបទល្មើស ដែលក្នុងនោះចារីម្នាក់ក្នុងចំណោមចារីដទៃទៀតប្រព្រឹត្តបទល្មើសមួយនៅក្រៅពីផែនការរួម ដែលទោះយ៉ាងណាក៏ដោយបទល្មើសនោះជាបច្ច័យពីធម្មជាតិ និង ដែលអាចមើលឃើញទុកជាមុននៃផលប៉ះពាល់នៃគោលបំណងឧក្រិដ្ឋរួមនោះ"[25]។

3. ធាតុផ្សំសត្យានុម័ត (*actus reus*) ដែលជាលក្ខខណ្ឌតម្រូវជារួមដូចៗគ្នាសម្រាប់ទម្រង់ទាំងបីមានអាទិ៍៖ (១) "មានមនុស្សច្រើននាក់" (២) "អត្ថិភាពនៃផែនការ ឬ គោលបំណងឧក្រិដ្ឋរួមដែលបង្កើតបាន ឬ ពាក់ព័ន្ធជាមួយការប្រព្រឹត្តបទល្មើសដែលចែងនៅក្នុងច្បាប់" និង (៣) "ការចូលរួមរបស់ជនជាប់ចោទនៅក្នុងផែនការឧក្រិដ្ឋរួមដែលពាក់ព័ន្ធជាមួយការប្រព្រឹត្តបទល្មើសមួយក្នុងចំណោមបទល្មើសចែងនៅក្នុងច្បាប់"[26] ដែលហាក់ដូចជា "សំខាន់"[27] ។

---

[23] ករណីយោងខាងលើ កថាខណ្ឌទី ១៩៦ ។ សូមមើលផងដែរ*ករណីវិវាទអាជ្ញា តទល់ជាមួយ Vasiljević*, IT-98-32-A សាលដីកាចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ [ ចាប់ពីពេលនេះតទៅហៅថាសាលដីកា *Vasiljević* ] កថាខណ្ឌ៩៧ ។

[24] ករណីវិវាទអាជ្ញា តទល់ជាមួយ *Kvočka* et al., IT-98-30/1-A សាលដីកាចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ [ ចាប់ពីពេលនេះតទៅហៅថាសាលដីកា *Kvočka* ] កថាខណ្ឌ២០៤ ។

[25] សាលដីកា *Vasiljević* កថាខណ្ឌ៩៩ ។ សូមមើលផងដែរសាលដីកា *Tadić* កថាខណ្ឌ២០៤ ។

[26] សាលដីកា *Kvočka* កថាខណ្ឌ២២៧ ។

[27] ករណីវិវាទអាជ្ញា តទល់ជាមួយ *Brđanin*, IT-99-36-A សាលដីកាចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ ។[ ចាប់ពីពេលនេះតទៅហៅថាសាលដីកា Brđanin] កថាខណ្ឌ៤៣០ ។

4. ធាតុផ្សំអត្តនោម័ត (mens rea) របស់ទម្រង់ទាំងបី គឺខុសគ្នា ។ ធាតុផ្សំអត្តនោម័តដែលជាលក្ខខណ្ឌតម្រូវសម្រាប់ សហឧក្រិដ្ឋកម្មរួម (JCE) I គឺមានចេតនារួមរវាងសមាជិកទាំងអស់ដើម្បីប្រព្រឹត្តបទល្មើសជាក់លាក់មួយ[28] ។ ចំពោះសហឧក្រិដ្ឋកម្មរួម (JCE) II ធាតុផ្សំអត្តនោម័តដែលជាលក្ខខណ្ឌតម្រូវ គឺ (ក) ការដឹងដោយផ្ទាល់នូវប្រព័ន្ធនៃការធ្វើទុក្ខបុកម្នេញ និង(ខ) "ចេតនាបណ្តោយការធ្វើទុក្ខបុកម្នេញកើតមានឡើង"[29]។ ចំពោះ សហឧក្រិដ្ឋកម្មរួម (JCE) III ធាតុផ្សំនៃបំណងឧក្រិដ្ឋដែលជាលក្ខខណ្ឌតម្រូវ គឺ "ចេតនាចូលរួម និងបណ្តោយឲ្យទង្វើប្រព្រឹត្តបទល្មើស ឬគោលបំណងឧក្រិដ្ឋនៃក្រុមមួយកើតឡើង និងចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម (JCE) ឬនៅក្នុងប្រព្រឹត្តិការណ៍ណាមួយចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដោយក្រុម"[30] ។ "ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសមួយ ក្រៅពីបទល្មើសដែលត្រូវបានឯកភាពនៅក្នុងផែនការរួម កើតមានឡើង ប្រសិនបើ (i) វា អាចមើលឃើញទុកជាមុន ថាបទល្មើសបែបនេះអាចត្រូវបានប្រព្រឹត្ត [...] និង (ii) ជនជាប់ចោទមាន<u>ចេតនាទទួលហានិភ័យនោះ</u>"[31]។ ការធ្វេសប្រហែសយ៉ាងធ្ងន់ធ្ងរ (*Dolus eventualis)* គឺជាបទដ្ឋានតម្រូវដែលមានលក្ខណៈសំខាន់ជាងការធ្វេសប្រហែសធម្មតាតែមួយមុខ[32] ។

5. ការពិពណ៌នាអំពីទម្រង់នៃការទទួលខុសត្រូវរបស់សហឧក្រិដ្ឋកម្មរួម (JCE) និងភាពខុសគ្នានៃធាតុផ្សំនីមួយៗដូចពិពណ៌នាពីខាងលើអាចបញ្ជាក់ថា ទ្រង់ទ្រាយនៃទម្រង់នៃការទទួលខុសត្រូវរបស់ សហកម្មឧក្រិដ្ឋកម្មរួម (JCE) នេះ គឺច្បាស់លាស់ និងមិនប្រែប្រួល។ មិនមានអ្វីលើសពីការពិតជាងនេះទៀតទេ[33] ។ ក្នុងតថភាពជាក់ស្តែង ចាប់តាំងពីការណែនាំ សហកម្មឧក្រិដ្ឋកម្មរួម (JCE) ទៅក្នុងយុត្តាធិការរបស់តុលាការពិសេសចំពោះកិច្ច (ad hoc) ភាពបត់បែនរបស់វាមានការប្រែប្រួលយ៉ាងខ្លាំង ។ ជាការពិត ការបង្កើតសហឧក្រិដ្ឋកម្មរួម (JCE) ដោយតុលាការដែលជាទម្រង់នៃការទទួលខុសត្រូវបែបទ្រឹស្តី ត្រូវបានថ្កោលទោសយ៉ាងខ្លាំងខ្លា ។ ឧទាហរណ៍ ចៅក្រម Per-Johan Lindholm បានកត់សំគាល់នៅក្នុងយោបល់ជំទាស់មួយផ្នែករបស់គាត់នៅក្នុងករណី *Simić* ថា៖

---

[28] សាលដីកា *Tadić* កថាខណ្ឌ២២៨ ។ សូមមើលផងដែរ សាលដីកា *Vasiljević* កថាខណ្ឌ ១០១ ។

[29] សាលដីកា *Tadić* កថាខណ្ឌ២២៨ ។សូមមើលផងដែរ សាលដីកា *Kvočka* កថាខណ្ឌ ២០៤ ។

[30] សាលដីកា *Tadić* កថាខណ្ឌ២២៨ ។

[31] ដូចខាងលើ (បញ្ជាក់បន្ថែម) ។

[32] សាលដីកា *Tadić* កថាខណ្ឌ២២០ ។ សូមមើលផងដែរ សាលដីកា *Kvočka* កថាខណ្ឌ ៨៣ យោង សាលដីកា *Tadić* កថាខណ្ឌ២០៤

[33] សូមមើលមតិយោបល់ផ្សេងៗគ្នាដែលបានសំដែងនៅក្នុងសាលដីកា *Brđanin* ។

> ខ្ញុំសូមដកខ្លួនចេញពីទស្សនៈ ឬ ទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម (JCE)នៅក្នុងករណីនេះ ក៏ដូច ជាករណីទូទៅដែរ ។ អ្វីដែលហៅថាទម្រង់ជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម (JCE) មិន [...] មានធាតុផ្សំអ្វីក្នុងទំរង់នេះឡើយ ។ វាគ្រាន់តែជាស្លាកឈ្មោះថ្មីបិទភ្ជាប់ទស្សនាទាន ឬ ទ្រឹស្តីដែលមានឈ្មោះបោះសម្លេងជាយូរមកហើយនៅក្នុងយុត្តាធិការភាគច្រើន ក៏ដូច ជាច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺការប្រព្រឹត្តបទល្មើសរួមគ្នា[34] ។

សាស្ត្រាចារ្យ Dershowitz បានពិពណ៌នា JCE ថាជា"ការប្រមូលផ្តុំ ព្រមជាមួយនឹងការ លាតសន្ធឹងនៃទម្រង់ទាំងប្រាំ អនុញ្ញាតអោយរដ្ឋអាជ្ញា និង ចៅក្រមបូកបញ្ចូលលភស្តុតាងប្រឆាំង លើជនជាប់ចោទដោយខុសច្បាប់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទចំពោះឧក្រិដ្ឋកម្មដែលមានលក្ខណៈ ទូទៅមួយចំនួន ដោយគ្មានភស្តុតាងដែលថា ជនជាប់ចោទធ្វើ "ផែនការ", "បានញុះញង់", "បាន

---

[34] ករណី*រដ្ឋអាជ្ញាតទល់ជាមួយ Simić et al.*, IT-95-9-T យោបល់ជំទាស់ដោយឡែក និង មួយផ្នែករបស់ចៅក្រម Per-Johan Lindholm ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ [ចាប់ពីពេលនេះតទៅហៅថាមតិយោបល់ចៅក្រម Lindholm] កថាខណ្ឌ២ ។ ការប្រព្រឹត្តរួមគ្នា (Co-perpetrationship) ក៏ត្រូវបានសំអាងដោយអង្គជំនុំជម្រះ Stakić ប៉ុន្តែត្រូវបាន បដិសេធដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ Stakić ។ សូមមើល*ករណីរដ្ឋអាជ្ញាតទល់ជាមួយ Stakić*, IT-97-24-T សាលក្រមចុះថ្ងៃ ទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌទី៤៣៨ ដល់ទី៤៤២ និង*ករណីរដ្ឋអាជ្ញាតទល់ជាមួយ Stakić*, IT-97-24-A សាលដីកាចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ៦២ ។ ប៉ុន្តែចៅក្រម Schomburg (ប្រធានក្រុមប្រឹក្សា ជំនុំជម្រះនៅក្នុងករណី *Stakić*) រក្សាជំហររបស់គាត់ក្នុងករណី *Stakić* នៅក្នុងយោបល់ជំទាស់របស់គាត់នៅក្នុងករណី *Simić*: ថាទស្សនៈនៃសហឧក្រិដ្ឋកម្មរួម (JCE) គឺ "អាចបកស្រាយបានតែការប្រព្រឹត្តបទល្មើសកំណត់នៅក្នុងលក្ខន្តិកៈ" ហើយថា "នៅក្រោមប្រព័ន្ធច្បាប់ជាច្រើនផ្សេងទៀត ការប្រព្រឹត្តបទល្មើសត្រូវបានបកស្រាយខុសគ្នាពីយុត្តិសាស្ត្ររបស់ តុលាការ ។ ចាប់តាំងពីតុលាការ Nuremberg និង Tokyo មកទាំងច្បាប់ព្រហ្មទណ្ឌជាតិ និង ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បានទទួលស្គាល់ជាពិសេសការប្រព្រឹត្តរួមគ្នា (Co-perpetrationship) ជាទម្រង់នៃការប្រព្រឹត្តបទល្មើស" ។ ករណី រដ្ឋអាជ្ញាតទល់ជាមួយ ***Simić*** IT-95-9-A យោបល់ជំទាស់របស់ចៅក្រម Schomburg ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ១២ និង១៤ ចៅក្រម Schomburg ក្នុងចំណោមបញ្ហាដទៃទៀត ផ្អែកលើការរកឃើញរបស់គាត់ទាក់ទងនឹងការ សិក្សាដែលធ្វើឡើងដោយវិទ្យាស្ថាន Max-Planck-Institute ពិនិត្យស្ថានភាពនានាដែលរួមការប្រព្រឹត្តរួមគ្នានៅក្នុង យុត្តាធិការជាតិ ។ របាយការណ៍នេះរៀបចំឡើងដោយវិទ្យាស្ថាន Max-Planck <u>តាមសំណើរបស់ការិយាល័យអ្យការ ICTY </u>។ សូមមើលអត្ថបទក្រោមចំណងជើងថា "ការចូលរួមនៅក្នុងឧក្រិដ្ឋកម្ម៖ ការទទួលខុសត្រូវរបស់មេដឹកនាំនៃក្រុម ឧក្រិដ្ឋកម្ម និងបណ្តាញ Participation in Crime: Criminal Liability of Leaders of Criminal Groups and Networks មតិយោបល់របស់អ្នកជំនាញ ដែលផ្តល់ដោយអង្គការសហប្រជាជាតិ-តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ អតីតយូហ្គោស្លាវី គំរោងសម្របសម្រួលនៃការិយាល័យព្រះរាជអាជ្ញា: សាស្ត្រាចារ្យ Dr. Ulrich Sieber., Priv. Doz. Dr. Hans Georg Koch, Jan Michael Simon វិទ្យាស្ថាន Max Planck Institut für ausländisches und internationales Strafrecht, Freiburg, Germany [ចាប់ពីពេលនេះទៅហៅថា ការចូលរួមក្នុងឧក្រិដ្ឋកម្ម]។

បញ្ញា", "បានប្រព្រឹត្ត" ឬ "បានសម្របសម្រួលនិងផ្តល់ជំនួយ" ទូវអំពើឧក្រិដ្ឋជាក់លាក់ណាមួយ"[35] ។ សាស្ត្រាចារ្យ Danner និង Martinez បានរកឃើញថា សហឧក្រិដ្ឋកម្មរួម (JCE) "លើកតម្កើងភាពអស្ចារ្យនៃពិរុទ្ធភាពតាមរយៈការចងក្រងជាបក្សពួក និងផ្តល់ប្រដាប់ចម្បាំងដល់អ្នកដែលមិនជឿរទុកចិត្តទៅលើភាពម៉ឺងម៉ាត់ និងភាពឥតលំអៀងនៃវេទិកាអន្តរជាតិ"[36] ខណៈពេលដែលលោកសាស្ត្រាចារ្យ Schabas បានកំណត់ សហឧក្រិដ្ឋកម្មរួម (JCE) ជា "គ្រាប់កាំភ្លើងដ៏សក្តិសិទ្ធិរបស់រដ្ឋអាជ្ញា" ដោយលើកហេតុផលថាការអនុវត្ត សហឧក្រិដ្ឋកម្មរួម (JCE) នឹងផ្តល់លទ្ធភាពឲ្យរដ្ឋអាជ្ញា

---

[35] ករណី*ព្រះរាជអាជ្ញាតទល់ជាមួយ Krajišnik,* IT-00-39-A, សារណាស្តីពីសហកម្មឧក្រិដ្ឋកម្មរួមក្នុងនាម Momčilo Krajišnik ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ៤ ។ ចំពោះការកត់សំគាល់ស្រដៀងគ្នានេះ សូមមើលអត្ថបទរបស់ Mohamed Elewa Badar ក្រោមចំណងជើងថា "ផ្តន្ទាទោសមនុស្សគ្រប់រូប" (Just Convict Everyone!)- ការប្រព្រឹត្តរួមគ្នា: ចាប់ពី *Tadić* ទៅដល់ *Stakić* 293 Int'l Crim. L. Rev. 301 (2006).។ "ការប្រភពនៃព្រួយបារម្ភទាក់ទងនឹងការអនុវត្ត CJE III... គឺថា... អ្នកចូលរួមត្រូវទទួលខុសត្រូវយ៉ាងអយុត្តិធម៌ចំពោះអំពើព្រហ្មទណ្ឌដែលគាត់ពុំមានបំណង ហើយក៏មិនបានចូលរួមដែរ ។ វាក៏អយុត្តិធម៌ដែលថា ការទទួលខុសត្រូវរបស់ចារី (អ្នកដែលប្រព្រឹត្តបទល្មើសដែលនៅខាងក្រៅផែនការរួម) ត្រូវបានវាយតំលៃយ៉ាងអន្តោម៉ត រីឯអ្នកចូលរួមវិញ ត្រូវបានវាយតំលៃឥតលំអៀង ។ សំខាន់ជាងនេះទៅទៀត ប្រសិនបើជនជាប់ចោទពិតជាបានចូលរួមក្នុងបទល្មើសខាងក្រៅផែនការដំបូង "គោលបំណងរួម" ជាអ្នកសម្របសម្រួលឬអ្នកផ្តល់ជំនួយ ពួកគេនឹងមានឱកាសរួចផុតពីការចោទប្រកាន់ដោយមិនអាចប្រកែកបាន ខណៈដែលអយ្យការនឹងបញ្ឈមមុខជាមួយការបង្ហាញភស្តុតាងដើម្បីគាំទ្រដល់ស្មារតីយល់ដឹងកម្រិតខ្ពស់ ជាពិសេស ជនជាប់ចោទដឹងអំពីតម្រូវការនៃស្ថានភាពស្មារតីរបស់មេក្លោងទាក់ទង នឹងបទករល្មើសដែលចោទប្រកាន់ ។ជាចុងក្រោយ ហើយកាន់តែដុនដាបថែមទៀតសហឧក្រិដ្ឋកម្មរួម (JCE) III (Extended form) ត្រូវបានប្រើប្រាស់ ដើម្បីផ្តន្ទាទោសអ្នកចូលរួមនៅក្នុងផែនការរួមសម្រាប់បទល្មើសដែលប្រព្រឹត្តដោយចារី ប្រសិនបើចារីពុំមានស្ថានភាពស្មារតីឬចេតនាពិរុទ្ធដែលជាលក្ខខណ្ឌតម្រូវសម្រាប់បទល្មើសដែលចោទប្រកាន់ (ជាពិសេសគោលបំណងព្រហ្មទណ្ឌជាក់លាក់)" ។

[36] សូមមើលស្នាដៃរបស់ Allison Marston Danner & Jenny S. Martinez, *ពិរុទ្ធភាពដោយសារតែការចងក្រងជាបក្សពួក (Guilty Associations): សហកម្មឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវជាមេបញ្ជាការ និង ការវិវឌ្ឍន៍នៃច្បាប់ប្រហ្មទណ្ឌអន្តរជាតិ (Joint Criminal Enterprise, Command Responsibility, and the Development of International Criminal Law)*, 93 Cal. L. Rev. 75, 137 (2005). ។ លោក Marston Danner & Jenny S. Martinez បានគត់សំគាល់បន្ថែមទៀតថា "ប្រសិនបើការសមគំនិត គឺជាចំណង់ចំណូលចិត្តរបស់រដ្ឋអាជ្ញាសហរដ្ឋអាមេរិកពិតមែន នោះវាពិបាកនឹងយល់ថាតើ សហឧក្រិដ្ឋកម្មរួម (JCE) អាចបង្កើតបានជាអ្វីមួយដែលតិចជាគ្រាប់បែកនុយក្លេអ៊ែររបស់ឃ្លាំងស្តុកអាវុធរបស់រដ្ឋអាជ្ញាអន្តរជាតិ" ។

សម្រេចបាននូវ "ការផ្តន្ទាទោសដោយស្រួលៗ"[37] (discounted convictions) ។ សហឧក្រិដ្ឋកម្មរួម (JCE) ដែលត្រូវបានសន្មតថាជាទ្រឹស្តីច្បាប់ទំនៀមទំលាប់អន្តរជាតិ ត្រូវគេបន្ធូរ ឬ បំព្រួញ អាស្រ័យលើសេចក្តីត្រូវការដើម្បីបិទបាំងស្ថានភាពអង្គហេតុដែលអាចមើលឃើញជាមុនបានរបស់រឿងក្តីហើយកាន់ តែគំរាមកំហែងខ្លាំងឡើងថែមទៀតនោះ នៅពេលពន្លឿនការសម្រេចនូវលទ្ធផលដែលរំពឹងទុក ។

II. ទម្រង់នៃការទទួលខុសត្រូវនៅអង្គជំនុំជម្រះវិសាមញ្ញ

1. ច្បាប់បង្កើត អ.វ.ត.ក ដែលចូលជាធរមាននៅឆ្នាំ២០០៤ ក្រោយអង្គជំនុំជម្រះតុលាការកំពូល *Tadić* បានបង្កើតទទួលខុសត្រូវរបស់សហឧក្រិដ្ឋកម្មរួម (JCE) នៅឆ្នាំ១៩៩៩ មិនបានបញ្ចូលសហឧក្រិដ្ឋកម្មរួម (JCE) ជាទម្រង់នៃការទទួលខុសត្រូវ ។ មាត្រា២៩ នៃច្បាប់ អ.វ.ត.ក ដាក់ការទទួលខុសត្រូវចំពោះជនសង្ស័យទាំងឡាយណា ដែល "មានផែនការញុះញង់, បញ្ជា, ប្រព្រឹត្ត ឬ ជួយនិងជំរុញ ឬ ប្រព្រឹត្ត" ឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ផ្ទុយទៅវិញ លក្ខន្តិកៈតុលាការ ICC ដែលអនុម័តនៅឆ្នាំ១៩៩៨ ចែងពីតុលាការ ICC យ៉ាងច្បាស់[38] ។

III. ច្បាប់សារជាតិអនុវត្តនៅ អ.វ.ត.ក

7. អ.វ.ត.ក អនុវត្តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងច្បាប់ជាតិរបស់ប្រទេសកម្ពុជា។ មាត្រា ២ នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា៖

> ត្រូវបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការ ដែលមានស្រាប់ ពោលគឺ សាលាដំបូង និង តុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការ

---

[37] សូមមើលស្នាដៃរបស់លោកសាស្ត្រាចារ្យ William A. Schabas ក្រោមចំណងជើងថា "ចេតនាពិរុទ្ធ និង តុលាការអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (*Mens Rea and the International Tribunal for the Former Yugoslavia)* 37 New Eng. L. Rev. 1025, 1032-34 (2003) ។

[38] មាត្រា ២៥(៣)(ឃ) នៃលក្ខន្តិកៈតុលាការ ICC អានផ្នែកដែលពាក់ព័ន្ធ "តាមមធ្យោបាយណាមួយផ្សេងទៀត រួមចំណែកក្នុងការប្រព្រឹត្ត ឬ ប៉ុនប៉ងប្រព្រឹត្តឧក្រិដ្ឋកម្មដោយជនមួយក្រុម ដោយធ្វើអំពើនោះឡើងក្នុងគោលបំណងរួម ។ ការចូលរួមចំណែកបែប នោះត្រូវតែមានចេតនា ហើយត្រូវ៖ (១)បានធ្វើឡើងដោយមានបំណងជំរុញនូវសកម្មភាពឧក្រិដ្ឋ ឬគោលបំណងឧក្រិដ្ឋរបស់ក្រុម នៅពេលដែលសកម្មភាព ឬ គោលបំណងបែបនេះពាក់ព័ន្ធជាមួយការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ឬ(២) បានធ្វើឡើងដោយដឹងអំពីចេតនារបស់ក្រុមដើម្បីប្រព្រឹត្តបទឧក្រិដ្ឋ" ។ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនបានដាក់បញ្ចូល... 

រំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់ មនុស្សធម៌អន្តរជាតិ និង ទម្លាប់អន្តរជាតិ និង ការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែល ប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩[39]។

ក. ច្បាប់កម្ពុជា

8. ច្បាប់កម្ពុជាដែលបានយោងនៅក្នុងមាត្រា២ គឺក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[40]។ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងពីទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលអាចអនុវត្តចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុង ឆ្នាំ១៩៧៥។ ច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺសំដៅទៅលើការចូលរួមដោយផ្ទាល់ ដែលចាត់ទុកជាសហចារី ហើយការរួមប្រព្រឹត្តដោយប្រយោល ទុកជាការសមគំនិត[41]។

9. ការរួមប្រព្រឹត្តគ្របដណ្តប់ស្ថានភាពដែលបុគ្គលពីរ ឬច្រើននាក់ ត្រូវបានពិចារណាដូចៗគ្នាថាជាអាទិចារី ហើយសហចារីម្នាក់ៗមាន *ចេតនាឧក្រិដ្ឋ (mens rea)* ជាចាំបាច់ និងបានបំពេញ *អំពើពិរុទ្ធ (actus reus)* ដ៏ចាំបាច់នៃ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្ត។ ការរួមប្រព្រឹត្តដោយប្រយោល ឬការសមគំនិត ដែលចែងបន្ថែមក្នុងមាត្រា ៨៣[42] រៀបរាប់ពី "ការមធ្យោបាយ" និង "ការជួយ ឬ ការទំនុកបំរុង" ជាទម្រង់ផ្សេងៗ[43]។

---

39 សេចក្តីបញ្ជាក់ត្រូវបានបន្ថែម ។

40 ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣។

41 មាត្រា២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា៖ "ជនណាចូលរួមប្រព្រឹត្តដោយចេតនានូវឧក្រិដ្ឋកម្ម ទោសកម្មណាមួយដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ជននោះត្រូវមានទោស ដូចជា អាទិចារី។ ការរួមប្រព្រឹត្តដោយផ្ទាល់នោះទុកជាសហចារី ឯការរួមប្រព្រឹត្តដោយប្រយោលទុកជា ការសមគំនិត។

42 មាត្រា ៨៣ ចែងថា: "ការរួមប្រព្រឹត្តដោយប្រយោយ ឬដោយសមគំនិត និងអាចមានទោសបាន ក៏លុះតែអំពើនោះបានសម្រេចមកពីការនាំអាទិ៍ ការឱ្យអនុទ្ទេស ការផ្តល់មធ្យោបាយ ការជួយ ឬការទំនុកបំរុង"។

43 ដោយសារក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បានយោងយ៉ាងខ្លាំងទៅលើក្រមព្រហ្មទណ្ឌបារាំង ប្រសិនបើមិនទាំងស្រុងនោះទេ នោះគេបានស្នើសុំឱ្យពិនិត្យមើលពីរបៀបដែលបទប្បញ្ញត្តិក្រមព្រហ្មទណ្ឌបារាំងស្តីពីបទសមគំនិត ត្រូវបានបកស្រាយ។ មាត្រា ១២១-៧ នៃក្រមព្រហ្មទណ្ឌបារាំងកំណត់និយមន័យ សមគំនិត ដូចតទៅ។ "ជនសមគំនិតចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម គឺជាជនដែលបានជួយទំនុកបំរុង សម្របសម្រួល ការរៀបចំ ឬការព្រព្រឹត្តដោយដឹងជាមុន។ ជនទាំងឡាយណាដែល តាមរយៈការផ្តល់ជារង្វាន់ ការសន្យា ការគំរាមកំហែង ការបញ្ជា ឬការរំលោភបំពានសមត្ថកិច្ច ឬអំណាច ការញុះញង់ឱ្យ មានការប្រព្រឹត្តបទល្មើស ឬផ្តល់ការណែនាំឱ្យប្រព្រឹត្តបទល្មើស ក៏ជាជនសមគំនិតដូចគ្នាដែរ"។ ច្បាប់បារាំងហាក់ពិចារណា "fourniture des moyens" (ការផ្តល់មធ្យោបាយ) ថាជាផ្នែកនៃ "aide ou assistance" (ការទំនុកបំរុង)

10. ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម (JCE) គឺមានភាពខុសគ្នារវាងការរួមប្រព្រឹត្ត និង ការសមគំនិត នៅក្រោមច្បាប់កម្ពុជា។

### ១. ភាពខុសគ្នារវាងការទទួលខុសត្រូវដោយផ្ទាល់នៅក្រោមច្បាប់កម្ពុជា និង សហឧក្រិដ្ឋកម្មរួម (JCE)

11. ទីមួយ ការរួមប្រព្រឹត្តទាមទារឱ្យមានវត្តមានរបស់សហចារីម្នាក់ៗនៅកន្លែងប្រព្រឹត្តកើតហេតុ។ នេះគឺដោយសារថា ដើម្បីភ្ជាប់ការទទួលខុសត្រូវ សហចារីម្នាក់ៗត្រូវតែបានសម្រេចផ្ទាល់ខ្លួននូវសកម្មភាពខាងសម្ភារៈដែលបង្កើតបានជាបទល្មើស[44]។ ផ្ទុយទៅវិញមានការលើកឡើងថា វត្តមានរបស់សមាជិកសហឧក្រិដ្ឋកម្មរួម (JCE) មិនតម្រូវនោះទេចំពោះការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ជនជាប់ចោទនៅក្រោមសហឧក្រិដ្ឋកម្មរួម (JCE)[45]។

12. ទីពីរ ដោយសារថាការចូលរួមប្រព្រឹត្តតម្រូវឱ្យសហចារីម្នាក់ៗបានសម្រេចដោយផ្ទាល់ខ្លួននូវសកម្មភាពខាងសម្ភារៈដើម្បីបង្កបានជាបទល្មើស នោះសហចារីអាចមិនប្រើអ្នកផ្សេងទៀតដែលមិនមែនជាសហចារីឱ្យប្រព្រឹត្តបទល្មើសដោយផ្ទាល់ខ្លួននោះទេ។ ផ្ទុយទៅវិញ មានការលើកឡើង ថា មេក្លោង ឬចារីប្រព្រឹត្តផ្ទាល់ដែរអាចនៅក្រៅសហឧក្រិដ្ឋកម្មរួម (JCE) ប្រសិនបើបានប្រើប្រាស់ដោយសមាជិកសហឧក្រិដ្ឋកម្មរួម (JCE) នោះ[46]។

13. ទីបី ការទទួលខុសត្រូវនៅក្នុងសហឧក្រិដ្ឋកម្មរួម (JCE) បែងចែករវាងផែនការរួមដែលបានចោទប្រកាន់ទៅជាគោលបំណង ពីមធ្យោបាយដែលបានគិតទុកដើម្បីសម្រេចគោលបំណងនោះ។ ផ្ទុយទៅវិញ ការរួមប្រព្រឹត្តហាក់មិនញែកចំនុចទាំងពីរនេះទេ[47]។

---

ដែលហាក់សង្កត់ធ្ងន់ទៅលើការផ្តល់ជំនួយជាក់ស្តែងទៅឱ្យចារី ដូចជា ការផ្តល់អាវុធ, Crim. 17 mai 1962: Bull. crim. No. 200; D. 1962. 473; ឬការផ្តល់រថយន្តទៅឱ្យអ្នកបើកបរដែលស្រវឹង, Alger, ២០ តុលា ១៩៦៥: Gaz. Pal. 1966.1. 133 ។ វាមាននៅក្នុង ការបោះពុម្ពផ្សាយលើកទី ១០៥ នៃក្រមព្រហ្មទណ្ឌ ២០០៨ នៅក្រោមផ្នែក "aide ou assistance" (ការទំនុកបំរុង) ។

44 B. Bouloc, Droit Pénal Général 267 (Dalloz, 2007), កថាខ័ណ្ឌ ២៩៣។

45 *រឿងអាជ្ញា តទល់នឹង Krnojelac*, IT-97-25-A, សាលក្រមចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៥ កថាខ័ណ្ឌទី ២៩៣។

46 សាលដីកា *Brđani* កថាខ័ណ្ឌ ១៩១។

47 ផលវិបាកនៃការញែកពីគ្នានេះគឺថា ជនម្នាក់អាចទទួលខុសត្រូវនៅក្រោមការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម (JCE) នៅពេលដែលទង្វើដូចគ្នា នេះអាចមិនមែនជាអំពើព្រហ្មទណ្ឌនៅក្រោមការប្រព្រឹត្តរួមគ្នា។ ទីមួយ នៅពេល"ដែលជនជាប់ចោទបានចូលរួមទៅក្នុងការលើកតម្កើងគោលបំណងរួមចំពោះខ្លឹមសារនៃ សហឧក្រិដ្ឋកម្មរួម (JCE)" នោះចំនុច

២. ភាពខុសគ្នារវាងការទទួលខុសត្រូវក្នុងបទសមគំនិតនៅក្រោមច្បាប់កម្ពុជា និង សហឧក្រិដ្ឋកម្មរួម (JCE)

14. ទីមួយ ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម (JCE) ត្រូវបានពិចារណាថាជាទម្រង់មួយនៃ "ការប្រព្រឹត្ត"[48]។ ផ្ទុយទៅវិញ អ្នកជួយនិងបង្កលក្ខណៈ គឺជា "អ្នកសមគំនិតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយ បុគ្គលផ្សេង[49]"។

---

នេះវាគ្រប់គ្រាន់ដើម្បីភ្ជាប់ទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ សាលដីកា *Brđani* កថាខ័ណ្ឌ ៤២៧។ ប៉ុន្តែ សម្រាប់ការចូលរួមប្រព្រឹត្ត តម្រូវឲ្យសមាជិកម្នាក់ៗសម្រេចដោយ ផ្ទាល់ខ្លួននូវសកម្មភាពខាងសម្ភារៈដែលបង្កើតបានជាបទល្មើស មានន័យថា ជាចំណែកនៃ*ពិរុទ្ធភាព*របស់បទល្មើស។ Bouloc, លេខសម្គាល់អក្សរយោងទី៤៤ ខាងលើ ដែលឋិតនៅទំព័រ២៦៧ កថាខ័ណ្ឌ២៨៣ ។ ដូចដែលបានលើកឡើងខាងលើ ចំនុចនេះបានញែកសហឧក្រិដ្ឋកម្មរួម (JCE) យ៉ាងច្បាស់ចេញពីសកម្មភាពរួមខាងដើម ដែលគ្មានផ្នែកណានៃ*អំពើពិរុទ្ធ*ត្រូវបានប្រព្រឹត្តឡើង នោះទេ។ សាលដីកា *Brđani* កថាខ័ណ្ឌ ៤២៧។ ទីពីរ ដោយការបង្ហាញពីភាពខុសគ្នារវាងគោលបំណង និង មធ្យោបាយ ដែលត្រូវបានប្រើប្រាស់ដើម្បីនោះការទទួលខុសត្រូវអាចចំពោះ សហឧក្រិដ្ឋកម្មរួម (JCE) នៅពេលដែលសហកម្មដែលបានចោទប្រកាន់គឺជា "វិសាលភាពដ៏ទូលំទូលាយ"។ *ផ្លូវអាជ្ញា តទល់នឹង Karamera* និងអ្នកផ្សេងទៀត, ICTR-98-44-AR72.5 & ICTR-98-44-AR72.6, សេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងយុត្តាធិការ៖ សហកម្មឧក្រិដ្ឋកម្មរួម ថ្ងៃទី១២ មេសា ២០០៦ កថាខ័ណ្ឌ១៦ ។ នេះដោយសារថានៅក្នុង សហឧក្រិដ្ឋកម្មរួម (JCE) គោលបំណងវាមិនច្បាស់លាស់"ក្នុងការធ្វើសកម្មភាពណាមួយចាំបាច់ដើម្បីទទួលបាន និងអនុវត្តអំណាចនយោបាយ និងត្រួតត្រាទៅលើទឹកដី"។ *ផ្លូវអាជ្ញា តទល់នឹង Brima* និងអ្នកផ្សេងទៀត, SCSL-04-16-T, សាលក្រមចុះថ្ងៃទី២០ មិថុនា ២០០៧ កថាខ័ណ្ឌ៦៧។ ផ្ទុយទៅវិញ ដោយសារថាគោលបំណង និងមធ្យោបាយ ដើម្បីសម្រេចគោលបំណងនោះ ដូចគ្នាបេះបិទនៅក្នុងការចូលរួមប្រព្រឹត្ត នោះមានតែសកម្មភាពខាងព្រហ្មទណ្ឌដែលជនជាប់ចោទ និងសហចារីផ្សេងទៀតមាននៅដោយផ្ទាល់ និងការដឹងដោយផ្ទាល់ខ្លួនអាចឋិតនៅក្រោមទម្រង់នៃការទទួលខុសត្រូវនេះ។ ទីបី ជនម្នាក់អាចនៅតែទទួលខុសត្រូវនៅក្រោមទ្រឹស្តី សហឧក្រិដ្ឋកម្មរួម (JCE) នៅពេលគោលបំណងនោះមិនមែនជាឧក្រិដ្ឋកម្មអន្តរជាតិ ប្រសិនបើមធ្យោបាយដែលបានគិតទុកដើម្បីសម្រេចគោលបំណងនោះគឺជាអំពើព្រហ្មទណ្ឌ។ *ផ្លូវអាជ្ញា តទល់នឹង Brima* និងអ្នកផ្សេងទៀត, SCSL-04-16-A, សាលក្រមចុះថ្ងៃទី២២ កុម្ភៈ ២០០៨ កថាខ័ណ្ឌ៧៦។ ផ្ទុយទៅវិញ ការចូលរួមប្រព្រឹត្ត នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អាចអនុវត្តជាទម្រង់នៃការទទួលខុសត្រូវបានតែក្នុងករណីដែលគោលបំណងនោះជា ឧក្រិដ្ឋកម្មអន្តរជាតិ ដោយសារថាវាត្រូវតែដូចគ្នានៅក្នុងមធ្យោបាយដែលបានគិតទុកដើម្បីសម្រេចគោលបំណងនោះ។

48 *ផ្លូវអាជ្ញា តទល់នឹង Milutinović* និងអ្នកផ្សេងទៀត, IT-99-37-AR72, សេចក្តីសម្រេចទៅលើបណ្តឹងរបស់ Dragoljub Ojdanić ជំទាស់ទៅនឹងយុត្តាធិការ - សហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២១ ឧសភា ២០០៣ [ហៅថា "សេចក្តីសម្រេច *Ojdanić* សហឧក្រិដ្ឋកម្មរួម (JCE)] កថាខ័ណ្ឌ២០។

49 សាលដីកា *Tadić* កថាខ័ណ្ឌ ២២៩ ។

15. ទីពីរ ខុសពីសហឧក្រិដ្ឋកម្មរួម (JCE) "ការជួយ និងការបង្កលក្ខណៈ" ឬ "ការផ្ដល់មធ្យោបាយ" មិនតម្រូវឱ្យបង្ហាញ ភស្តុតាងនៃផែនការរួមនោះទេ៖ អាទិចារី អាចនឹងមិនដឹងពីការចូលរួមរបស់អ្នកសមគំនិតផង[50]។

16. ទីបី *ធាតុចេតនា*ដែលតម្រូវឱ្យមានចំពោះ"ការជួយ និងការបង្កលក្ខណៈ" ឬ "ការផ្ដល់មធ្យោបាយ" គឺការដឹងថាអំពើទាំងនោះជួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម[51]។ ផ្ទុយទៅវិញ ការទទួលខុសត្រូវនៅក្នុងសហឧក្រិដ្ឋកម្មរួម (JCE) តម្រូវថា សហចារីមានបំណងថា ឧក្រិដ្ឋកម្មនោះនឹងត្រូវបានប្រព្រឹត្ត (សហឧក្រិដ្ឋកម្មរួម (JCE) I) ឬមាន "ចេតនាដើម្បីធ្វើឱ្យផែនការឧក្រិដ្ឋកម្មរួមនោះ ជាមួយនឹងការយល់ឃើញហេតុការណ៍ជាមុនថា ឧក្រិដ្ឋកម្មដែលនៅក្រៅគោលបំណងឧក្រិដ្ឋកម្មរួម អាចត្រូវបានប្រព្រឹត្ត" (សហឧក្រិដ្ឋកម្មរួម (JCE) III)[52]។

**ខ. ច្បាប់មនុស្សធម៌អន្តរជាតិ និង ទំនៀមទម្លាប់**

17. ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចតាក់តែងឡើងតែតាមរយៈ (ក) ការទម្លាប់អនុវត្តជាទូទៅ និងជាប់លាប់របស់រដ្ឋ[53] (ខ) ទស្សនៈដែលថា ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ *(opinio juris)*[54]។

---

50 ដូចគ្នា ។

51 មាត្រា៨០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា: "ការផ្ដល់មធ្យោបាយ" ត្រូវតែបាន "ផ្ដល់ដោយដឹងថា" មធ្យោបាយទាំងនោះត្រូវបានប្រើប្រាស់ដើម្បីគោលបំណងនោះ"។ (<u>មានបន្ថែមសេចក្ដីបញ្ជាក់</u>)។ មាត្រា ៨៧ ចែងថា: "ជំនួយ ឬ ការទំនុកបំរុង ត្រូវបានផ្ដល់ជូន<u>ដោយដឹងច្បាស់ថា</u>នឹងជួយរៀបចំ ឬសម្រួលដល់សកម្មភាពប្រព្រឹត្ត"។ (<u>មានបន្ថែមសេចក្ដីបញ្ជាក់</u>)។

52 សាលដីកា *Tadić* កថាខ័ណ្ឌ ២២៩ ។

53 ទាក់ទិនទៅនឹងការអនុវត្តរបស់រដ្ឋ ICJ បានលើកឡើងថា "ភាគីដែលសំអាងទៅលើទំនៀមទម្លាប់...ត្រូវបង្ហាញថាទំនៀមទម្លាប់នេះត្រូវបានបង្កើតឡើងនៅក្នុងលក្ខណៈមួយ ដែលទំនៀមទម្លាប់នេះក្លាយទៅជាការចងកាតព្វកិច្ចទៅលើភាគីដទៃទៀត ...[និង]ថា វិធានដែលទំនៀមទម្លាប់នេះបានសំអាងនោះត្រូវស្របតាមទម្លាប់ប្រើប្រាស់ខ្ជាប់ខ្ជួន និងដូចគ្នាដែលអនុវត្តដោយរដ្ឋ ..."។ *ករណីសុំសិទ្ធិជ្រកកោនរបស់កូឡុំប៊ី-ប៉េរូ* សាលក្រមចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥០, របាយការណ៍របស់ ICJ ឆ្នាំ១៩៥០ ទំព័រ២៧៦ ។ ការអនុវត្តរបស់រដ្ឋគួរតែ"មានភាពដូចគ្នាទូលំទូលាយ និងចាំបាច់ចំពោះបទប្បញ្ញត្តិដែលបានយោង"។ *រឿងក្ដីរវាងប្រទេសនីការ៉ាហ្គ័រ តទល់នឹង សហរដ្ឋអាមេរិក* (អង្គហេតុ) របាយការណ៍របស់ ICJ ឆ្នាំ១៩៨៦ កថាខ័ណ្ឌ ៧៤។

54 សម្រាប់ទស្សនៈដែលថា ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ *(opinio juris)*, តុលាការ ICJ បានលើកឡើងថា រដ្ឋទាំងឡាយ "ត្រូវតែប្រព្រឹត្តឱ្យបានត្រឹមត្រូវ ដូច្នោះ ទង្វើរបស់ខ្លួនគឺជា ភស្តុតាងនៃជំនឿដែលថា ការអនុវត្តនេះត្រូវបានដាក់ចេញជាចំណងកាតព្វកិច្ចដោយអត្ថិភាពនៃនីតិរដ្ឋដែលតម្រូវឱ្យមានចំណងកាតព្វកិច្ចនេះ។ *រឿងក្ដីរវាងប្រទេសនីការ៉ាហ្គ័រ តទល់នឹង សហរដ្ឋអាមេរិក* (អង្គហេតុ), របាយការណ៍របស់ ICJ ឆ្នាំ១៩៨៦ កថាខ័ណ្ឌ ១៤។

ដូចដែលបានបង្កើតនៅក្នុងរឿងក្តីរបស់ *Tadić,* សហឧក្រិដ្ឋកម្មរួម (JCE) បានផ្ទុះបញ្ចាំងឱ្យឃើញថា អង្គជំនុំជម្រះតុលាការកំពូលមិនបានធ្វើការវិភាគឱ្យបានហ្មត់ចត់ ទាំងការទម្លាប់អនុវត្តរបស់រដ្ឋ និង ទាំងទស្សនៈដែលថា ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ *(opinio juris)*[55]។

### 1. សហឧក្រិដ្ឋកម្មរួម (JCE) ដែលបានបង្កើតនៅក្នុងរឿងក្តី *Tadić* មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ

18. ក្នុងការឈានដល់ការធ្វើសេចក្តីសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួម (JCE) ត្រូវបានបង្កើតឡើងនៅក្នុង ច្បាប់ទំនៀមទម្លាប់អន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Tadić* បានសំអាងទៅលើ រឿងក្តីមួយចំនួន តូចតែប៉ុណ្ណោះពីចំនួនយុត្តាធិការដែលមានចំនួនកំណត់[56]។ ការពិនិត្យឡើងវិញតែរឿង ក្តីដែលមាន ចំនួនកំណត់ពីប្រព័ន្ធច្បាប់ដ៏តិចតួចបែបនេះ មិនបានឆ្លើយតបទៅនឹងការធ្វើតេស្តល្អិតល្អន់

---

[55] នៅក្នុងការផ្តល់គំនិតយោបល់របស់អ្នកជំនាញ ដែលប្រគល់អំណាចឱ្យដោយការិយាល័យរដ្ឋអាជ្ញានៃតុលាការ ICTY គេ បានសម្រេចថា រដ្ឋគាត់ច្រើនប្រើ សហចារី ជាជាង សហឧក្រិដ្ឋកម្មរួម (JCE)។ *សូមមើល* ការចូលរួមនៅក្នុងបទល្មើស នៅក្នុងអក្សរយោង *ខាងលើលេខ* ៣៤។ *សូមមើល*ផងដែរនូវរឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង* *Gacumbitsi*, ICTR-2001-64-A, សាលដីកា, យោបល់ដាច់ដោយឡែករបស់ចៅក្រម Schomburg ទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អ្នក ប្តឹងឧទ្ធរណ៍ចំពោះ ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ កថាខ័ណ្ឌ២៤។ "[នៅពេល] បកស្រាយអត្ថន័យនៃ "ការប្រព្រឹត្ត" ដែលបានសំអាងទៅលើការទទួលខុសត្រូវដែលបានដាក់បន្ទុក នោះវាជាកាតព្វកិច្ច ប្រកបដោយកិត្តិយសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីដាក់បញ្ចូល និងធ្វើជារួមនូវប្រព័ន្ធច្បាប់ធំៗរបស់ពិភពលោក នេះ និងទទួលយកផងដែរនូវការរីកចំរើនដែលបានទទួលស្គាល់នៅក្នុងច្បាប់ព្រហ្មទណ្ឌ ក្នុងប៉ុន្មានទសវត្សកន្លងទៅនេះ"។

[56] ទាក់ទិនទៅនឹង សហឧក្រិដ្ឋកម្មរួម (JCE) I អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី *Tadić* បានសំអាងទៅលើរឿងក្តី ចំនួនប្រាំមួយតែប៉ុណ្ណោះ ដែលរឿងក្តីចំនួនបួនយកចេញពីតុលាការយោធាអង់គ្លេស មួយមកពីតុលាការប្រទេសកាណាដា និងមួយទៀតមកពី តុលាការអាមេរិកកាំង: *Otto Sandrock* និងបីផ្សេងទៀត; *Hoelzer* និងអ្នកផ្សេងទៀត; *Gustav Alfred Jepsen* និងអ្នកផ្សេងទៀត; *Franz Schonfeld* និងអ្នកផ្សេងទៀត; *Feurstein* និងអ្នកផ្សេងទៀត; *Otto Ohlenforf* និងអ្នកផ្សេងទៀតទាក់ទិននឹងសហឧក្រិដ្ឋកម្មរួម (JCE) II ។ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Tadić* បានសំអាងលើរឿងក្តីពីរនៅ ក្នុងសាលក្រមគឺរឿងក្តីនៅជំរុំប្រមូលផ្តុំនៅ Dachau (ការកាត់ក្តីរបស់ *Martin Gottfried Weiss* ***និងអ្នកផ្សេងទៀតចំនួន សាមសិបប្រាំបួននាក់***) និងរឿងក្តី Belsen (ការកាត់ក្តីរបស់ *Josef Kramer* ***និងអ្នកផ្សេងទៀតចំនួនសែសិបបួននាក់***)។ សម្រាប់ សហឧក្រិដ្ឋកម្មរួម (JCE) III អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿង ក្តី *Tadić* បានសំអាងទៅលើរឿងក្តី *Essen Lynching,* រឿងក្តី *Borkum Island,* សេចក្តីសម្រេចមិនបានបោះពុម្ពផ្សាយ មួយចំនួនពីយុត្តាធិការប្រទេសអ៊ីតាលីក្រោយសង្គ្រាមលោកលើក ទីពីរគឺ *Repubblica Sociale Italiana; D'Ottavio et al; Aratano et al; Tossani; Ferrida; Bonati et al, Mannelli*។

ដើម្បីធ្វើយុត្តិកម្មលើការបង្កើត សហឧក្រិដ្ឋកម្មរួម (JCE) ដោយតុលាការ និងឋានៈទំនៀមទម្លាប់របស់វា សហឧក្រិដ្ឋកម្មរួម (JCE) នោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានសំអាងទៅលើអនុសញ្ញាអន្តរជាតិចំនួនពីរផងដែរគឺ អនុសញ្ញាអន្តរជាតិដើម្បីបង្ក្រាបការបំផ្ទុះគ្រាប់ដោយពួកភេរវក (ICSTB)[57] និងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ហៅថា លក្ខន្តិកៈតុលាការ ICC)[58] ។ ក្នុងយោបល់ខ្វែងគំនិតគ្នាដោយផ្នែក និងសេចក្តីប្រកាសរបស់គាត់នៅក្នុងរឿងក្តី *Orić* ចៅក្រមឈ្មោះ Liu បានលើកឡើងថា "ដោយសារតែច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវប៉ាន់ប្រមាណពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស នោះជាការពិតគឺថា ... អត្ថបទច្បាប់ទាំងនោះត្រូវបានអនុម័តក្រោយកាលបរិច្ឆេទទាំងនេះ នោះច្បាប់ទាំងនោះកម្រិតទម្ងន់ និងសារៈប្រយោជន៍របស់វាថាជាប្រភពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើង[59]។ អនុសញ្ញាទាំងពីរនេះត្រូវបានព្រាង ចុះហត្ថលេខា និងចូលជាធរមានក្រោយកាលបរិច្ឆេទនៃការប្រព្រឹត្ត

---

57 G.A. Res. 164, U.N. GAOR, 52nd Sess., Supp. No. 49, at 389, U.N. Doc. A/52/49 (1998).

58 ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ មាត្រា២៥, 2187 U.N.T.S. 3, 105.

59 *សូមមើល រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង Orić*, IT-03-68-A, សាលដីកាចុះថ្ងៃទី៣ កក្កដា ២០០៨, យោបល់ខ្វែងគំនិតគ្នាដោយផ្នែក និងសេចក្តីប្រសកាសរបស់ចៅក្រម Liu កថាខ័ណ្ឌ ២៦ ដែលយោងទៅលើអត្ថបទនៃសេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងមកលើសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ និងមាត្រា ២៨ នៃលក្ខន្តិកៈ ICC ដែលត្រូវបានអនុម័តក្រោយការអនុម័តលក្ខន្តិកៈ ICTY និង ICTR ។ សូមមើលផងដែរនូវ*រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង Hadžihasanović* និង *Kubura*, IT-01-47-AR72, សេចក្តីសម្រេចទៅលើបណ្តឹងបន្ទាន់បង្គិតវ៉ាទៅលើយុត្តាធិការដែលទាក់ទងទៅនឹងការទទួលខុសត្រូវក្នុងតួនាទីជាមេបញ្ជាការ [បន្ទាប់ពីនេះតទៅហៅថា បណ្តឹងបន្ទាន់បង្គំ *Hadžihasanović* ] ដែលមានយោបល់ផ្ទុយគ្នាក្នុងក្នុងផ្នែកខ្លះរបស់ចៅក្រម Shahabuddeen ចុះថ្ងៃទី១៦ កក្កដា ២០០៣ កថាខ័ណ្ឌ២១ ដែលចៅក្រម Shahabuddeen បានលើកឡើងថា "តាមការពិតទៅ ត្រូវផ្តល់ទម្ងន់ដល់អត្ថបទច្បាប់ទាំងអស់ឲ្យដូចជាការបង្ហុលបង្ហាញរបស់រដ្ឋចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលដែលច្បាប់ទាំងអស់នេះត្រូវបានអនុម័តរួចហើយនោះ។ ប៉ុន្តែដោយសារថាអត្ថបទច្បាប់ទាំងអស់នេះ [សេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងមកលើសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ] ត្រូវបានអនុម័តក្រោយការតាក់តែងលក្ខន្តិកៈរបស់តុលាការនេះ និងក្រោយកាលបរិច្ឆេទនៃអំពើដែលបានចោទប្រកាន់ ...ត្រូវបានប្រព្រឹត្តឡើង នោះបញ្ហាថាតើស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទៅលើឱកាសទាំងនេះយ៉ាងដូចម្តេចនោះវាហាក់ដូចជាមិននិយាយដល់ករណីយុត្តិសាស្ត្រ ដូចបទប្បញ្ញត្តិមុនៗ...នៃពិធីសារបន្ថែមទី I ទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩" នោះទេ។

បទល្មើសនៅក្នុងរឿងក្តី *Tadić*។ ហេតុដូច្នេះហើយ វាមានតម្លៃតិចតួចបំផុត (ប្រសិនបើមាន) នៅក្នុងការប៉ាន់ប្រមាណពី ឋានៈទំនៀមទម្លាប់អន្តរជាតិរបស់ JCE[60]។

19. មិនមែនតែអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី *Tadić* ប៉ុណ្ណោះទេ ដែលសំអាងសេចក្តី សម្រេចរបស់ខ្លួនទៅលើចរិតលក្ខណៈជាទំនៀមទម្លាប់នៃសហឧក្រិដ្ឋកម្មរួម (JCE) ស្តីពីករណីយុត្តិសាស្ត្រដែលមាន ចំនួនកម្រិតបំផុត គឺករណីយុត្តិសាស្ត្រទាំងឡាយដែលខ្លួនបានពិនិត្យឃើញថាមិនសមស្របឬសូម្បីតែមិនគាំទ្រដល់ទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់នេះទៀតផង ។ ក្នុងចំណោមបញ្ហាដទៃទៀត រឿងក្តីទាំងនេះបង្ហាញពីការអនុវត្តមិនស៊ីសង្វាក់គ្នានៃធាតុចេតនា ឬការខកខាន របស់ចៅក្រមក្នុងការលើកឡើងពីច្បាប់នេះ[61]។ លើសពីនេះទៅទៀត នៅក្នុងរឿងក្តីខ្លះ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Tadić* បានសន្មត់ថា ទឡ្ហីករណ៍របស់រដ្ឋអាជ្ញាទាក់ទិនទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ត្រូវបានយកមកអនុវត្តតាមដោយសារថា ជនជាប់ចោទត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ[62]។ សាមញ្ញជាងនេះទៅទៀតនោះ នៅក្នុងរឿងក្តីដែលបានសំអាងដោយអង្គជំនុំជម្រះ "ស្ទើតែមិនបានគាំទ្រដល់ចំនុចខ្វែងគំនិតគ្នាភាគច្រើននៃទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមសហកាល[63]។

---

[60] បទល្មើសនៅក្នុងរឿងក្តី *Tadić* ត្រូវបានប្រព្រឹត្តនៅក្នុងឆ្នាំ១៩៩២ ។ ICSTB ត្រូវបានអនុម័តដោយសម្លេងភាគច្រើននៃមហាសន្និបាតអង្គការសហប្រជាជាតិតាមរយៈសេចក្តីសម្រេចលេខ ៥២/១៦៤ ចុះថ្ងៃទី១៥ ធ្នូ ១៩៩៧ និងបានបើកចំហរឲ្យចុះហត្ថលេខានៅថ្ងៃទី១២ មករា ១៩៩៨ និងចូលជាធរមាននៅថ្ងៃទី២៣ ឧសភា ២០០១។ លក្ខន្តិកៈ ICC ចូលជាធរមាននៅឆ្នាំ២០០២ ។

[61] សាលដីកាក្នុងរឿងក្តី *Tadić* កថាខ័ណ្ឌ ២០៨ និង ២១២ ។

[62] ឧទាហរណ៍ នៅក្នុងការពិនិត្យរឿងក្តី *Essen Lynching* ឡើងវិញអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសន្មតមិនសមហេតុផលថាដោយសារចុងចោទត្រូវបានផ្តន្ទាទោស នោះតុលាការត្រូវទទួលយកទឡ្ហីករណ៍របស់រដ្ឋអាជ្ញាទាក់ទិនទៅនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខ័ណ្ឌ ២០៨។

[63] ករណីទាំងអស់ដែលបានលើកឡើងនៅក្នុងរឿងក្តី *Tadić*.......... មិនបានគាំទ្រដល់ទម្រង់ដ៏ទូលំទូលាយនៃ សហឧក្រិដ្ឋកម្មរួម (JCE) នោះទេ ជាពិសេស ទម្រង់លាតសន្ធឹងនៃការទទួលខុសត្រូវបែបនេះ ដែលសព្វថ្ងៃត្រូវបានប្រើប្រាស់នៅនៅ ICTY ។ ផ្ទុយទៅវិញ ករណីដែលបានពិភាក្សានៅក្នុងរឿងក្តី *Tadić* ឋិតនៅក្នុងប្រភេទមួយនៃប្រភេទចំនួនពីរ។ ប្រភេទទីមួយ ពាក់ព័ន្ធនឹងការ សម្លាប់ក្រៅផ្លូវច្បាប់ទៅលើក្រុមតូចៗនៃអ្នកទោសសង្គ្រាមសម្ព័ន្ធមិត្ត អាចសម្លាប់ដោយទាហានអាឡឺម៉ង់ ឬដោយទាហាន អាឡឺម៉ង់ និងប្រជាជនអាឡឺម៉ង់ដែលរស់ទីក្រុង។ ប្រភេទទីពីរនៃករណី ទាំងនេះទាក់ទងនឹងជំរុំឃុំខ្លួន....។ ពុំមានការចង្អុល បង្ហាញនៅក្នុង [*Essen Lynching*] ឲ្យឃើញថា រដ្ឋអាជ្ញាបានសំអាងច្បាស់លាស់ទៅលើទស្សនៈនៃការរៀបចំផែនការរួម គោលបំណងរួម ឬផែនការរួមនោះទេ។ ទោះជាយ៉ាងណាក៏ដោយ តុលាការក្នុងរឿងក្តី

20. ការបង្កើតទំរង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃសហឧក្រិដ្ឋកម្មរួម JCE ឃើញថាមិនមានការគាំទ្រនៅក្នុងសារធាតុនៃអនុសញ្ញាអន្តរជាតិទាំងពីរ ដែលផ្អែកដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Tadić* ។ អនុសញ្ញា ICSBT ទាក់ទងជាមួយឧក្រិដ្ឋកម្មជាងច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY ហើយសូម្បីច្បាប់លក្ខន្តិកៈរបស់តុលាការ ICC ដែលបញ្ចូលការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃសហឧក្រិដ្ឋកម្មរួម (JCE) ក៏ ICC បដិសេធនូវការបកស្រាយរបស់តុលាការ ICTY អំពីការអនុវត្តនៃ សហឧក្រិដ្ឋកម្មរួម (JCE) ដែរ[64]។ ដូច្នេះ អនុសញ្ញាទាំងពីរនេះមិនប្រើប្រាស់ជាមូលដ្ឋានសំរាប់ការបង្កើតសហឧក្រិដ្ឋកម្មរួម (JCE) ទេ។

21. ការយោងទៅលើសេចក្តីសំរេចរបស់ខ្លួនពីមុនស្តីពីថានៈទំនៀមទំលាប់នៃសហឧក្រិដ្ឋកម្មរួម (JCE) ដូចដែលតុលាការ ICTY ធ្វើទាក់ទងនឹងរាល់សាលក្រម ឬសេចក្តីសំរេចដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់សហឧក្រិដ្ឋកម្មរួម (JCE) មិនមានបង្ហាញភស្តុតាងអ្វីច្រើនជាងអ្វីដែលអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY គឺស៊ីសង្វាក់គ្នានៅខាងក្នុង។ ប៉ុន្តែ បើសិនជាការបង្កើត សហឧក្រិដ្ឋកម្មរួម (JCE) នៅក្នុងរឿងក្តី *Tadić* មិនត្រឹមត្រូវដោយផ្អែកលើទំហំ ប្រភេទ ព្រំដែន និង ភាពស៊ីសង្វាក់នៃប្រភពមិនគ្រប់គ្រាន់ ដូច្នេះស្ថាប័នដែលបន្តធ្វើដដែលនូវភាពខុសឆ្គងនេះមិនបានកែតម្រូវវាឡើយ[65]។

22. ដោយបានបង្កើតនូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (ដែលដើរតួជាតុលាការជាន់ទីពីរសំរាប់តុលាការ ICTR ផងដែរ) បានបដិសេធមិនពិចារណា

---

*Tadić* បានលើកករណីនេះឡើង ដើម្បីគាំទ្រដល់ប្រភេទទីបីនៃ សហឧក្រិដ្ឋកម្មរួម (JCE)"។ Danner & Martinez, *supra* note 36, at 110-11 ។

64 *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់* Lubanga Dyilo ICC-01/04-01/06 សេចក្តីសំរេចស្តីពីសេចក្តីយល់ព្រមលើបទចោទប្រកាន់ ២៩ មករា ២០០៨ ។

65 ចៅក្រម Isaac Isaacs នៅក្នុងរឿងក្តីនៅចំពោះមុខតុលាការជាន់ខ្ពស់របស់អូស្ត្រាលី បានកត់សំគាល់ថា "បើសិនជាអញ្ចឹង យើងអាចរកឃើញច្បាប់មានវិវាទទាំងស្រុងជាមួយអ្វីដែលយើង ឬ ជំនាន់មុនរបស់យើងបានគិតមិនត្រឹមត្រូវ ថាវានឹងត្រូវដូច្នេះ ដូចយើងយល់ឃើញ យើងមិនមានសិទ្ធិដើម្បីជ្រើសរើសរវាងផ្តល់ប្រសិទ្ធិភាពដល់ច្បាប់ និងថែរក្សានូវការបកស្រាយមិនត្រឹមត្រូវ។ ជាយោបល់ខ្ញុំ វាមិនមានភាពប្រសើរដែលតុលាការគួរមានៈធ្វើមិនត្រឹមត្រូវ ជាជាងធ្វើអ្វីដែលត្រឹមត្រូវនៅទីបំផុត។ *រឿងក្តី ក្រុមហ៊ុនកសិកម្មអូស្ត្រាលី តទល់នឹង Federated Engine-Drivers & Firemen's Assn of Australasia* (1913), 17 C.L.R. 261 at 278 (Isaacs J)"

ការតតាំងនឹងការយល់ឃើញរបស់ខ្លួនស្តីពីធម្មជាតិជាប្រពៃណីនៃ សហឧក្រិដ្ឋកម្មរួម (JCE)[66] នៅក្នុងរឿងក្តី *Tadić* ។ ទោះបីជាហេតុផលមាំទាំមានច្រើនក្រៃលែង[67] ការបដិសេធនូវការយល់ឃើញក្នុងរឿងក្តី *Tadić* នឹងមានផលប៉ះពាល់ដ៏ធំធេងមកលើការចោទប្រកាន់ដែលធ្វើឡើងនៅតុលាការ ICTY ដោយសារទំហំនៃចំនួនការចោទប្រកាន់ដែលក្រោយមកបានពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួម JCE[68] ។

23. អ.វ.ត.ក និងជាពិសេស ក.ស.ច.ស នៅក្នុងករណីនេះ មិនចាំបាច់ និងមិនគួរទទួលយកមកពិចារណានូវការត្រិះរិះខាងនយោបាយបែបនេះឡើយ ។ ហេតុនេះ ការចាំបាច់សំរាប់ ក.ស.ច.ស គឺធ្វើការវិភាគដោយមិនគិតពីមនោសញ្ចេតនា ថាតើការទទួលខុសត្រូវតាមបែបសហឧក្រិដ្ឋកម្មរួម (JCE) គឺជាផ្នែកនៃច្បាប់ទំនៀមទំលាប់អន្តរជាតិដែរឬទេ។ ការវិភាគបែបនេះនឹងលាតត្រដាងថា វាមិនមែនជាផ្នែកនៃច្បាប់អន្តរជាតិប្រពៃណីទេ។

---

66 នៅពេលច្បាប់ទំនៀមទំលាប់ដែលជាមូលដ្ឋាននៃការទទួលខុសត្រូវតាមបែបសហឧក្រិដ្ឋកម្មរួម (JCE) ត្រូវបានតតាំងដោយផ្ទាល់ពីមេធាវីការពារនៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Milutinović et al.* អង្គជំនុំជម្រះតុលាការកំពូលបានត្រឹមតែពោលអះអាងថា វា"មិនមែនជាសំណើអោយពិនិត្យសើរើការយល់ឃើញរបស់ខ្លួននៅក្នុងរឿងក្តី *Tadić* ទាក់ទងនឹងស្ថានភាពប្រពៃណីនៃទំរង់នៃការទទួលខុសត្រូវនេះឡើយ"។ វាបានបំពេញគ្រប់គ្រាន់ថា *ទំលាប់អនុវត្តរបស់រដ្ឋ* (state practice) និង *ទស្សនៈដែលថាទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ (opinion juris)* ដែលត្រូវបានពិនិត្យឡើងវិញនៅក្នុងសេចក្តីសំរេចនោះមានលក្ខណៈគ្រប់គ្រាន់ដើម្បីអោយមានការសន្និដ្ឋានថា ទំនៀមទំលាប់បែបនោះកើតមានឡើងក្រោមច្បាប់ទំនៀមទំលាប់អន្តរជាតិក្នុងឆ្នាំ ១៩៩២ នៅពេលដែល *Tadić* បានប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានគេចោទប្រកាន់ និងឧក្រិដ្ឋដែលចុងបញ្ចប់ត្រូវរកឃើញថាមានទោស" សេចក្តីសំរេចស្តីពីសហឧក្រិដ្ឋកម្មរួម (JCE) កថាខណ្ឌ ២៩ ។

67 អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Aleksovski* បានថ្លែងយ៉ាងច្បាស់ថា "អង្គជំនុំជម្រះតុលាការកំពូលគួរយកតាមសេចក្តីសំរេចរបស់ខ្លួនពីមុន ប៉ុន្តែគួរមានសេរីភាពមិនយកតាមសេចក្តីសំរេចពីមុនចំពោះមូលហេតុសមហេតុផលមាំទាំក្នុងផលប្រយោជន៍នៃយុត្តិធម៌"។ ករណីនៃស្ថានភាពដែលមូលហេតុសមហេតុផលមាំទាំជាប្រយោជន៍នៃយុត្តិធម៌ តម្រូវអោយវៀរចាកពីសេចក្តីសំរេចមុនៗ រួមមានរឿងក្តីមួយចំនួនដែលសេចក្តីសំរេចមុនៗត្រូវបានសំរេចដោយឈរលើមូលដ្ឋាននៃ<u>គោលការណ៍ច្បាប់មិនត្រឹមត្រូវ</u> ឬ រឿងក្តីដែលសេចក្តីសំរេចមុនៗត្រូវសំរេចដោយផ្អែកតាមការផ្តល់ព័ត៌មានមិនត្រឹមត្រូវ (*per incuriam*) *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Aleksovski, IT-95-14/1-A សាលដីកាតុលាការកំពូល ចុះថ្ងៃទី ២៤ មីនា ២000 កថាខណ្ឌ ១០៧-០៨ (<u>មានបញ្ជាក់សេចក្តីបន្ថែម</u>) ។

68 បរិមាណនៃដីកាចោទប្រកាន់បឋមដែលមានបញ្ចូលការទទួលខុសត្រូវតាមបែបសហឧក្រិដ្ឋកម្មរួម (JCE) មានចំនួនគួរអោយភ្ញាក់ផ្អើល។ "ដីកាចោទប្រកាន់បឋមដំបូងបង្អស់ដែលផ្អែកលើសហឧក្រិដ្ឋកម្មរួម (JCE) ត្រូវបានទទួលយកនៅថ្ងៃទី ២៥ មិថុនា ២០០១ គឺ៨ឆ្នាំក្នុងការធ្វើការរបស់តុលាការ ICTY។ ក្នុងចំណោមដីកាចោទប្រកាន់បឋមចំនួន ៤២ ដែលបានធ្វើឡើងក្នុងចន្លោះពីថ្ងៃខាងលើនេះមកទល់នឹងថ្ងៃ ១ មករា ២០០៤ មាន២៧ ពឹងផ្អែកជាក់លាក់លើសហឧក្រិដ្ឋកម្មរួម (JCE)" កំណត់សំគាល់ពីមុនដដែល (*supra*) ៣៦ នៅ ១០៧-០៨ ។

**2. ទោះបីថា សហឧក្រិដ្ឋកម្មរួម (JCE) ឥឡូវត្រូវបានគេពិចារណាថាជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិក៏ដោយ តែវាមិនអាចអនុវត្តបាននៅ អ.វ.ត.ក ទេ**

**i) វាមិនមែនជាផ្នែកនៃច្បាប់ទំនៀមទំលាប់អន្តរជាតិនៅក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩**

24. ទោះបីជា សហឧក្រិដ្ឋកម្មរួម (JCE) អាចត្រូវបានគេពិចារណាថាជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិសម័យទំនើបក៏ដោយ តែវាមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិរវាងឆ្នាំ ១៩៧៥-៧៩ ដូច្នេះហើយ វាមិនអាចត្រូវបានគេប្រើប្រាស់ថាជាទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តក្នុងអំឡុងពេលនោះឡើយ។ ដើម្បីបង្កើតនូវអ្វីដែលត្រូវបានគេពិចារណាថាជាច្បាប់ទំនៀមទំលាប់អន្តរជាតិ រវាងឆ្នាំ ១៩៧៥-៧៩ អ.វ.ត.ក ដាច់ខាតត្រូវតែរកមើលយុត្តិសាស្ត្រដែលចុះកាលបរិច្ឆេទមុនរយៈកាលនោះ ដើម្បីស្វែងរក *ទំលាប់អនុវត្តរបស់រដ្ឋ* (state practice) និង *ទស្សនៈដែលថាទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ (opinion juris)* ដែលមានលក្ខណៈទូទៅ និងស៊ីសង្វាក់[69]។ មិនមានភស្តុតាងដែលថា យុត្តិសាស្ត្ររបស់តុលាការសឹក IMT ជាផ្នែកនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ រវាងឆ្នាំ ១៩៧៥-៧៩ ឡើយ។

---

[69] ទោះបីមេធាវីការពារទទួលស្គាល់ថា ប្រភពដ៏ច្រើនត្រូវបានដកស្រង់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងករណី *Tadić* ដើម្បីគាំទ្រការបង្កើតនូវការទទួលខុសត្រូវតាមបែបសហឧក្រិដ្ឋកម្មរួម (JCE) ដែលមានកាលបរិច្ឆេទមុនឆ្នាំ ១៩៧៥ វាក៏ធ្វើការយោងជាច្រើនទៅយុត្តិសាស្ត្រជាបន្តបន្ទាប់ ឬ ច្បាប់ក្នុងស្រុកដើម្បីជាមូលដ្ឋានសំរាប់ទំរង់នៃការទទួលខុសត្រូវនេះ។ ឧទាហរណ៍ លេខយោង (footnote) ទី ២៨៥-២៨៧ នៃសាលដីកាតុលាការកំពូលក្នុងរឿងក្តី *Tadić* ដកស្រង់ច្បាប់និងរឿងក្តីជាបន្តបន្ទាប់ដែលមានកាលបរិច្ឆេទក្រោយឆ្នាំ ១៩៧៥ ដូចជា៖ (១) ប្រទេសបារាំង លេខយោងទី ២៨៥ សេចក្តីសំរេចចុះថ្ងៃទី ១៩ មិថុនា ១៩៨៤ *Bulletin, ibid.,* ឆ្នាំ ១៩៨៤ លេខ ២៣១ ។ (២) ប្រទេសអ៊ីតាលី លេខយោងទី ២៨៦ សាលាឧក្រិដ្ឋ (Court of Cassation) ៣ មីនា ១៩៧៨ *Cassazione penale* ឆ្នាំ ១៩៨០ ទំព័រ ៤៥ *ff;* សាលាឧក្រិដ្ឋ ៤ មីនា ១៩៨៨ *Cassazione penale* ឆ្នាំ ១៩៩០ ទំព័រ ៣៥ *ff;* សាលាឧក្រិដ្ឋ ១១ តុលា ១៩៨៥ មីនា ១៩៨៨ *Rivista penale* ឆ្នាំ ១៩៨៦ ទំព័រ ៤២១ *ff;* សាលាឧក្រិដ្ឋ ១៨ កុម្ភៈ ១៩៩៨ ១៩៨៨ *Rivista penale* ឆ្នាំ ១៩៩៨ ទំព័រ ១២០០ *ff;* ។ (៣) ប្រទេសអង់គ្លេស និង វែល លេខយោងទី ២៨៧ *R. v. Hyde* [1991] 1 QB 134 *Hui Chi-Ming v. R.* [1992] 3 All ER 897 ។ (៤) ប្រទេសកាណាដា លេខយោងទី ២៨៨ *R. v. Logan* [1990] 2 SCR 731; *R. v. Rodney* [1990] 2 SCR 687 ។ (៥) ប្រទេសសហរដ្ឋអាមេរិច លេខយោងទី ២៨៩ Maine Criminal Code § 57 (1997), Minnesota Statutes § 609.05 (1998), Iowa Code § 703.2 (1997), Kansas Statutes § 21-3205 (1997),Wisconsin Statutes § 939.05 (West 1995); *State of Connecticut v. Diaz,* 237 Conn. 518, 679 A. 2d 902 (1996) ។ (៦) ប្រទេសអូស្ត្រាលី លេខយោងទី ២៩០ *McAuliffe v. R.* (1995) 183 CLR 108 ។ ដើម្បីវាយតម្លៃថាតើការទទួលខុសត្រូវតាមបែបសហឧក្រិដ្ឋកម្មរួម (JCE) គឺជាផ្នែកនៃច្បាប់ទំនៀមទំលាប់អន្តរជាតិដែលឬទេក្នុងឆ្នាំ ១៩៧៥ ទាំងនេះមិនគួរត្រូវគេពិចារណាទេ ដោយសារមូលហេតុដូចមានក្នុងលេខយោងទី ៥៩ ។

ការអះអាងដំបូងបង្អស់ថាមានឋានៈជាទំនៀមទំលាប់របស់វាគឺ របាយការណ៍របស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ស្តីពីការបង្កើតតុលាការ ICTY ។ របាយការណ៍ថ្លែងថា តុលាការ ICTY "គួរប្រើប្រាស់បណ្តាវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលវាលើសពីវិមតិសង្ស័យជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់" ហើយថា "ផ្នែកនៃច្បាប់មនុស្សធម៌អន្តរជាតិតាមការសន្ធត ដែលលើសពីវិមតិសង្ស័យក្លាយជាផ្នែកមួយនៃច្បាប់មនុស្សធម៌អន្តរជាតិគឺ ច្បាប់ដែលអនុវត្តបានក្នុងជំលោះប្រដាប់អាវុធដែលត្រូវបានបញ្ចូលក្នុង ... ធម្មនុញ្ញនៃតុលាការសឹកអន្តរជាតិ ៨ សីហា ១៩៤៥" [70]។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានដកស្រង់យករបាយការណ៍របស់អគ្គលេខាធិការ ដើម្បីបង្ហាញថាយុត្តិសាស្ត្ររបស់តុលាការសឹក IMT ត្រូវបានពិចារណាជាផ្នែកច្បាប់ទំនៀមទំលាប់អន្តរជាតិ ប៉ុន្តែមិនដកស្រង់យកប្រភពអ្វីផ្សេងទៀតដើម្បីគាំទ្រនូវសេចក្តីអះអាងនេះឡើយ[71]។ ជាការពិត វាប្រាកដជាធ្វើដូច្នេះ បើសិនជាមានអ្វីផ្សេងត្រូវដកស្រង់យក។ ដូច្នេះ ទោះបីជាធម្មនុញ្ញប្រហែលជាត្រូវបានពិចារណាថាជាច្បាប់ទំនៀមទំលាប់អន្តរជាតិនៅឆ្នាំ ១៩៩៣ ក៏ដោយ ក៏នេះមិនអាចប្រើប្រាស់ជាមូលដ្ឋានដើម្បីពិចារណាថាជាច្បាប់ទំនៀមទំលាប់អន្តរជាតិ រវាងឆ្នាំ ១៩៧៥-៧៩ ឡើយ។

### ii) ច្បាប់ទំនៀមទំលាប់អន្តរជាតិមិនអាចអនុវត្តដោយផ្ទាល់ក្នុងតុលាការកម្ពុជា

25. នៅពេលណាក៏ដោយ ដែលច្បាប់ទំនៀមទំលាប់អន្តរជាតិត្រូវបានស្នើអនុវត្តនៅក្នុងតុលាការក្នុងស្រុក តុលាការនោះអាចពិចារណា បើសិន និង ស្ថិតក្រោមកាលៈទេសៈអ្វីដែលប្រព័ន្ធច្បាប់ជាតិអនុវត្តច្បាប់ទំនៀមទំលាប់អន្តរជាតិ។ ក្នុងពេលដែលមិនមានការណែនាំជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញ បញ្ញត្តិច្បាប់ ឬ យុត្តិសាស្ត្រជាតិរបស់ខ្លួន តុលាការជាតិមិនត្រូវស្ថិតនៅក្រោមកាតព្វកិច្ចណាមួយដើម្បីអនុវត្តច្បាប់ទំនៀមទំលាប់អន្តរជាតិឡើយ[72]។

---

70 របាយការណ៍របស់អគ្គលេខធិការអង្គការសហប្រជាជាតិអនុលោមទៅតាមកថាខណ្ឌ ២ នៃដំណោះស្រាយលេខ ៨០៨ របស់ក្រុមប្រឹក្សាសន្តិសុខ (ឆ្នាំ ១៩៩៣) កថាខណ្ឌ ៣៤-៣៥ ។ គ្មានរបាយការណ៍ប្រហាក់ប្រហែលគ្នានេះកើតមានឡើងដើម្បីផ្តល់ពត៌មានដល់ អ.វ.ត.ក ថាតើអ្វីអាចនឹងត្រូវបានគេពិចារណាថាជាច្បាប់ទំនៀមទំលាប់អន្តរជាតិក្នុងរវាងឆ្នាំ ១៩៧៥-៧៩ ។

71 ដដែល (*Id.*)

72 *សូមមើល* Antonio Cassese, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ 303 (ការបោះពុម្ពផ្សាយរបស់សាកលវិទ្យាល័យ Oxford ឆ្នាំ 2003) "ជាធម្មតា តុលាការជាតិទាំងឡាយមិនអនុវត្តនីតិវិធីសំរាប់ឧក្រិដ្ឋកម្មអន្តរជាតិ ដោយឈរតែលើមូលដ្ឋាននៃច្បាប់*ទំនៀមទំលាប់*អន្តរជាតិទេ គឺថា បើឧក្រិដ្ឋកម្មមួយគ្រាន់តែមានចែងនៅក្នុងអត្ថបទច្បាប់នោះតែមួយមុខប៉ុណ្ណឹង។ ផ្ទុយទៅវិញ គេមាននិន្នាការតម្រូវអោយទាំងច្បាប់ជាតិអោយចែងនិយមន័យបទល្មើស និងទាំងអោយផ្តល់យុត្តាធិការតុលាការជាតិ

26. អ.វ.ត.ក ត្រូវបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់នៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់កម្ពុជា។ ជាការគួរអោយកត់សម្គាល់ថា គ្មានរដ្ឋធម្មនុញ្ញណាមួយរបស់កម្ពុជាមានចែងអំពីនីតិវិធីសំរាប់ធ្វើដូចម្តេចដើម្បីអោយច្បាប់ទំនៀមទំលាប់អន្តរជាតិត្រូវរួមបញ្ចូលទៅក្នុងច្បាប់ជាតិ[73]។ ច្បាប់រដ្ឋ

---

ទៅលើបទល្មើសនោះ ឬ បើសិនសន្ធិសញ្ញាមួយត្រូវបានផ្តល់សច្ចាប័នទៅលើរឿងនោះដោយរដ្ឋ ការអនុម័តយកនូវ *បទបញ្ញត្តិដែលមានលក្ខណៈអនុវត្ត* អនុញ្ញាតអោយតុលាការទាំងឡាយអនុវត្តដោយពេញលេញនូវបញ្ញត្តិនៃសន្ធិសញ្ញាដែលពាក់ព័ន្ធ"។ *សូមមើលផងដែរ រឿងក្តី* *Nulyarimma v. Thompson* [1999] FCA 1192,កថាខណ្ឌ ២២, ២៦ (តុលាការសហព័ន្ធរបស់ប្រទេសអូស្ត្រាលី) (យោបល់របស់ចៅក្រម Wilcox J.) "វាមិនគ្រប់គ្រាន់ទេដោយគ្រាន់តែនិយាយថា ក្រោមច្បាប់អន្តរជាតិ ឧក្រិដ្ឋកម្មអន្តរជាតិមួយអាចត្រូវបានផ្តន្ទាទោសដោយតុលាការក្នុងស្រុកសូម្បីតែមិនមានច្បាប់ក្នុងស្រុក ដែលប្រកាសថាទង្វើណាមួយនឹងអាចត្រូវគេផ្តន្ទាទោសបាននោះ។ បើសិនឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវចាត់ទុកថាអាចត្រូវផ្តន្ទាទោសបាននៅក្នុងប្រទេសអូស្ត្រាលី ដោយឈរលើមូលដ្ឋានថា វាគឺជាឧក្រិដ្ឋកម្មអន្តរជាតិ វាដាច់ខាតត្រូវតែបានបង្ហាញអោយឃើញថា ច្បាប់អូស្ត្រាលីអនុញ្ញាតអោយធ្វើដូច្នេះមែន (មានបញ្ជាក់សេចក្តីបន្ថែម) ។ *អត្ថបទដដែល* នៅកថាខណ្ឌ ២៦ "តុលាការក្នុងស្រុកទាំងឡាយប្រឈមមុខនឹងបញ្ហាគោលនយោបាយដើម្បីសំរេចថាតើត្រូវទទួលស្គាល់ និងអនុវត្តនូវវិធាននៃច្បាប់អន្តរជាតិ។ បើសិនជាមានបញ្ហាគោលនយោបាយបែបនេះ ខ្ញុំគ្មានអ្វីជាមន្ទិលឡើយថា វានឹងត្រូវដោះស្រាយនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ក្នុងពេលដែលមិនមានបញ្ញត្តិច្បាប់ ដោយបដិសេធមិនអនុវត្តនូវទំនៀមទំលាប់អន្តរជាតិនោះ"។ Gabriele Olivi *តួនាទីនៃតុលាការជាតិទាំងឡាយនៅក្នុងការវិនិច្ឆ័យទោសឧក្រិដ្ឋកម្មអន្តរជាតិ៖ ទស្សនាទានថ្មី* 18 Sri Lanka J. Int'l L. 83, 87 (2006) *ដោយដកស្រង់រឿងក្តី* *sans Frontières v. Mille Collines* សាលាឧទ្ធរណ៍ក្រុងប៉ារីស សាលដីកាចុះថ្ងៃទី ៦ វិច្ឆិកា ១៩៩៥ នៅ ៤៨-៥១ "ក្នុងពេលអវត្តមាននៃច្បាប់ក្នុងស្រុកច្បាប់ទំនៀមទំលាប់អន្តរជាតិ មិនអាចមានឥទ្ធិពលនៃការពង្រីកមកលើយុត្តាធិការក្រៅដែនដី តុលាការបារាំងឡើយ"។ *រឿងក្តី* *U.S. v. Yousef,* 327 F.3d 56, 91 (2nd Cir. 2003) "ច្បាប់របស់សហរដ្ឋអាមេរិចមិនស្ថិតនៅក្រោមអំណាចនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ ឬ ចាំបាច់ស្ថិតនៅក្រោមអំណាចនៃច្បាប់អន្តរជាតិដែលបង្កើតដោយសន្ធិសញ្ញា ហើយជាការពិត ប្រហែលជាមានទំនាស់រវាងករណីទាំងពីរនេះ"។

[73] គួរកត់សំគាល់ថា រវាងថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩ រដ្ឋធម្មនុញ្ញពីរស្ថិតនៅជាធរមាន។ ក្នុងកំឡុងពេលនៃរបបសាធារណៈខ្មែរ (១៩៧០-១៩៧៥) រដ្ឋធម្មនុញ្ញមួយត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី ១០ ឧសភា ១៩៧២ ។ រដ្ឋធម្មនុញ្ញរបស់របបសាធារណរដ្ឋខ្មែរ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដោយក្នុងនោះវាបានត្រឹមតែចែង ក្រោមមាត្រា ៣៨ ថា "ប្រធានាធិបតីនៃរបបសាធារណរដ្ឋចុះហត្ថលេខាលើសន្ធិសញ្ញា និង អនុសញ្ញា ហើយផ្តល់សច្ចាប័នលើ សន្ធិសញ្ញា និង អនុសញ្ញានោះ អនុលោមទៅតាមការបោះឆ្នោតរបស់សភា"។ មាត្រា ៧២ ហាមឃាត់ការអនុវត្តប្រតិសកម្មរបស់ច្បាប់ "លើកលែងសំរាប់ក្នុងបញ្ញត្តិពិសេសដែលត្រូវបានចែងយ៉ាងច្បាស់នៅទីនេះ"។ វាមិនមានបទបញ្ញត្តិណាមួយនៅក្នុងរដ្ឋធម្មនុញ្ញគាំទ្រនូវការអះអាងដែលថា ច្បាប់អន្តរជាតិអាចអនុវត្តបានដោយផ្ទាល់នៅក្នុងពេលនេះឡើយ។ រដ្ឋធម្មនុញ្ញថ្មីមួយមិនទាន់ប្រកាសអោយប្រើភ្លាមទេ តែក្រោយមកត្រូវបានប្រកាសនៅថ្ងៃទី ៥ មករា ១៩៧៦ ក្នុងកំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ អត្ថបទនៃរដ្ឋធម្មនុញ្ញនេះត្រូវបានអនុម័តក្នុងសម័យប្រជុំក្រុមមេបញ្ជាការនៅរដ្ឋធានីកម្ពុជា ចាប់ពីថ្ងៃទី ១៥ ដល់ ១៩ ធ្នូ ១៩៧៥ ដែលគោលការណ៍របស់វាត្រូវបានសំរេចយកនៅ

ធម្មនុញ្ញឆ្នាំ ១៩៩៣ បានត្រឹមតែចែងថា ព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខា និងផ្តល់សច្ចាប័នដល់អនុសញ្ញា និង សន្ធិសញ្ញាអន្តរជាតិ ក្រោយពីបានទទួលការអនុម័តយល់ព្រមពីសភាជាតិ និង ព្រឹទ្ធសភា[74]។ គ្មានការចែងអំពីការអនុវត្ត ឬ ការបញ្ចូលនូវច្បាប់ទំនៀមទំលាប់អន្តរជាតិត្រូវបានគេធ្វើឡើងសោះឡើយ។

27. មាត្រា ១ និង ២ នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងគោលបំណង "ដើម្បីវិនិច្ឆ័យទោស ... ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានដ៏ធ្ងន់ធ្ងរទៅលើ ... ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទំនៀមទំលាប់ ..."[75] ។ វាជាការចាំបាច់ដើម្បីរកមើលច្បាប់ទំនៀមទំលាប់ ដែលវិនិច្ឆ័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលឧក្រិដ្ឋកម្មទាំងនេះមានមូលដ្ឋាននៅក្នុងទំនៀមទំលាប់។ នេះមិនមានន័យថា គ្រប់ច្បាប់ទំនៀមទំលាប់អន្តរជាតិនឹងក្លាយទៅជាអនុវត្តបានក្នុងតុលាការកម្ពុជាឡើយ។ សហឧក្រិដ្ឋកម្មរួម (JCE) គឺជាទំរង់មួយនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងមិនមែនជាឧក្រិដ្ឋកម្មអន្តរជាតិទេ[76]។ វាមិនអាចទៅរួចឡើយ ក្នុងការរំលោភ

---

ចុងខែមេសា ។ *សូមមើល* Raoul M. Jennar បណ្តារដ្ឋធម្មនុញ្ញកម្ពុជា (១៩៥៣-១៩៩៣) (១៩៩៥)។ រដ្ឋធម្មនុញ្ញនេះបញ្ចូលនូវបញ្ញត្តិមានកំរិតដែលទាក់ទងនឹងក្របខណ្ឌបញ្ញត្តិច្បាប់ដែលអាចអនុវត្តបាននៅក្នុងអំឡុងពេលនេះ។ មិនមានបទបញ្ញត្តិណាមួយដែលទាក់ទងនឹងការអនុវត្តនូវច្បាប់អន្តរជាតិនៅក្នុងច្បាប់ក្នុងស្រុករបស់កម្ពុជាឡើយ។ មាត្រា ៥ បានត្រឹមតែចែងថា អំណាចនីតិបញ្ញត្តិត្រូវប្រគល់ទៅអោយសភាតំណាងប្រជាជន កម្មករ កសិករ និងពលករកម្ពុជាគ្រប់រូបដទៃទៀត។ មាត្រា ៧ អះអាងបញ្ជាក់ថា សភាតំណាងប្រជាជនទទួលខុសត្រូវខាងនីតិបញ្ញត្តិ និងកំណត់នូវគោលនយោបាយជាតិ និងអន្តរជាតិដទៃទៀតរបស់របបកម្ពុជាប្រជាធិបតេយ្យ។

[74] មាត្រា ២៦ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្មនៅខែមីនា ១៩៩៩ ចែងថា "ព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះក្រោយពីបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា"។

[75] (<u>មានបញ្ជាក់សេចក្តីបន្ថែម</u>)

[76] សាលដីកាតុលាការកំពូលក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៩១ *ដោយដកស្រង់* សេចក្តីសំរេចស្តីពីសហឧក្រិដ្ឋកម្មរួម (JCE) *Ojdanić* ក្នុងរឿងក្តី កថាខណ្ឌ ២០ ។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brđanin,* IT-99-36-A សេចក្តីសំរេចស្តីអំពីសាលដីកាចាត់របៀប ចុះថ្ងៃទី ១៩ មីនា ២០០៤ កថាខណ្ឌ ៥ ៖ "ប្រភេទទីបីនៃស្តីពីសហឧក្រិដ្ឋកម្មរួម (JCE) គឺ ... មិនមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មមួយជាក់លាក់។ វាគឺជា<u>ប្រភេទផែននៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ</u>តាមរយៈនេះជនជាប់ចោទអាចត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ដោយមិនចាំបាច់ជាអ្នកដៃដល់ក្នុងការប្រព្រឹត្តបទល្មើស"។ (<u>មានបញ្ជាក់សេចក្តីបន្ថែម</u>)

បំពានទំរង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដូច្នេះហើយបញ្ញត្តិច្បាប់មិនដាក់កាតព្វកិច្ចដល់ អ.វ.ត.ក អោយរកមើល និង អនុវត្តច្បាប់ទំនៀមទំលាប់អន្តរជាតិចំពោះបញ្ហានេះឡើយ[77]។

### iii) អនុសញ្ញាអន្តរជាតិ

28. អនុសញ្ញាអន្តរជាតិដែលមាននិយាយនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺ អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨ ដែលមានចែងនៅក្នុងមាត្រា ៤, អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដែលមានចែងក្នុងមាត្រា ៦ អនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៩៥៤ សំរាប់ការការពារសម្បត្តិវប្បធម៌នៅក្នុងព្រឹត្តការណ៍ជំលោះប្រដាប់អាវុធ ដែលមានចែងក្នុងមាត្រា ៧ និង អនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦១ ស្តីពីទំនាក់ទំនងការទូត ដែលមានចែងក្នុងមាត្រា ៨ ។ អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនអនុវត្តនៅទីនេះទេ ដោយសារអ្វីដែល ក.ស.ច.ស កត់សំគាល់ថា "អៀង សារី បច្ចុប្បន្នមិនទាន់ត្រូវចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅឡើយ[78]"។ គ្មានអនុសញ្ញាណាផ្សេងពីនេះដូចដែលបានរាយនាមនៅពីនេះពិភាក្សាពីទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។ អាស្រ័យហេតុនេះ សហឧក្រិដ្ឋកម្មរួម (JCE) ប្រហែលជាមិនអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងលោក អៀង សារី ឡើយ ដោយសារវាមិនមានមូលដ្ឋាននៅក្នុងអនុសញ្ញាអន្តរជាតិណាមួយ ដែលត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជា និង មិនអាចអនុវត្តដោយផ្ទាល់ប្រឆាំងនឹងបុគ្គលទាំងឡាយក្នុងរវាងឆ្នាំ ១៩៧៥-៧៩ ឡើយ។

## IV. ការបំពានគោលការណ៍ គ្មានបទល្មើសបើគ្មានច្បាប់ចែង (*nullum crimen sine lege)*

29. អ.វ.ត.ក ដោយរក្សាអ្វីដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ និងគោលការណ៍សិទ្ធិមនុស្សដែលគេទទួលស្គាល់ ត្រូវបានហាមឃាត់មិនអោយអនុវត្តច្បាប់ប្រតិសកម្មដែលមិនអាចអនុវត្តបាន និងមិនមានលក្ខណៈចាប់

---

[77] នៅតុលាការសឹកនូរ៉ឹមប៊ើក មានការពិភាក្សាថាតើការសមគំនិតក្នុងរឿងព្រហ្មទណ្ឌគួរត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មដែរឬទេ ដូចដែលវាជាឧក្រិដ្ឋកម្មក្នុងប្រព័ន្ធច្បាប់ អង់គ្លេ-អាមេរិចកាំង ដែលអាចធ្វើភាពសមាជិកនៅក្នុងការផ្សំគំនិតវាគ្រប់គ្រាន់ដើម្បីបង្ហាញនូវភស្តុតាងនៃពិរុទ្ធភាព។ ចៅក្រមជនជាតិបារាំង Donnedieu de Vabres បានជឿជាក់ថា ការណ៍នេះនឹងនាំទៅរកការបង្កើតនូវច្បាប់មុនអង្គហេតុ (ex pot facto law) ដែលការសមគំនិតជាឧក្រិដ្ឋកម្មមិនត្រូវបានទទួលស្គាល់នៅក្នុងច្បាប់បារាំងឡើយ។ នៅទីបញ្ចប់ ការសមគំនិតមិនត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្ម លើកលែងករណីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព។ សំរាប់ការវិភាគដែលមានលក្ខណៈប្រវត្តិសាស្ត្រលើបញ្ហានេះ *សូមមើល* Telford Taylor កាយវិភាគវិទ្យា(anatomy)នៃតុលាការសឹកនូរ៉ឹមប៊ើក 34-41, 550-53, 637-38, (Little, Brown & Co. 1992) ។

[78] រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ វិច្ឆិកា ២០០៧ កថាខណ្ឌ ទី៨

បង្ខំនៅក្នុងប្រទេសកម្ពុជា ពីឆ្នាំ ១៩៧៥-៧៩ ។ ដូច្នេះមានតែទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលលោក **អៀង សារី** ប្រហែលអាចត្រូវបានគេចោទប្រកាន់នោះគឺទម្រង់ទាំងឡាយដែលអាចអនុវត្តបានចំពោះគាត់ ពីឆ្នាំ ១៩៧៥-៧៩ ។ ការចោទប្រកាន់លោក **អៀង សារី** ក្រោមទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលមិនកើតមានពីមុននៅខណៈពេលឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមការស៊ើបសួរត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត រំលោភបំពានគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង ដែលហាមឃាត់ការអនុវត្តប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ[79]។ គោលការណ៍នេះត្រូវបានទទួលស្គាល់នៅក្នុងច្បាប់កម្ពុជាក្នុងស្រុក[80] និងមានលក្ខណៈចាប់បង្ខំក្រោមច្បាប់អន្តរជាតិមកលើកម្ពុជា[81]។

## V. **កម្មវិធាកបើសិនជាសហឧក្រិដ្ឋកម្មរួម (JCE) នឹងត្រូវបានគេប្រើប្រាស់នៅ អ.វ.ត.ក**

30. បើសិនជាទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយលក្ខណៈគ្រឹះមិនមានយុត្តិធម៌ និងមានលក្ខណៈសម្ពហភាព ត្រូវបានគេអនុវត្តនៅ អ.វ.ត.ក ដែលឈានពីនេះ ក.ស.ព នឹងអាចបាចសាចការប្រឡាក់ប្រឡូសទៅលើអ្នកដទៃទៀត ដោយអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ជាបច្ច័យ ថាតើដោយមានចេតនា ឬក៏អត់ ភាគច្រើននៃបុគ្គលទាំងអស់នេះដែលជាសមាជិកផ្សេងៗគ្នានៃសង្គមកម្ពុជា នឹងមិនអាចជៀសផុតពីការរាប់បញ្ចូលថាជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម (JCE) បានឡើយ។

---

[79] គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* (*nullum crimen sine lege*) ត្រូវអនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដូចជាចំពោះបទល្មើសដែរ ។ *សូមមើល* សាលដីកាតុលាការកំពូលក្នុងរឿងក្តី *Hadžihasanović* កថាខណ្ឌ ៣២-៣៥ ។

[80] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ មាត្រា ៦ កថាខណ្ឌ ១ "ច្បាប់ព្រហ្មទណ្ឌគ្មានអានុភាពប្រតិសកម្មទេ គឺថា បទល្មើសណាបានប្រព្រឹត្តមុនបទបញ្ញត្តិរបស់ច្បាប់ បទល្មើសនោះមិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ។"

[81] កម្ពុជាបានចុះហត្ថលេខលើកតិកាសញ្ញា ICCPR កាលពីថ្ងៃទី ១៧ តុលា ១៩៨០ ហើយត្រូវបានផ្តល់សច្ចាប័ននៅថ្ងៃទី ២៦ ឧសភា ១៩៩២ ។ មាត្រា ១៥(១) នៃកតិកាសញ្ញា ICCPR ចែងថា "គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពី ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តបទល្មើសនោះឡើយ"។

31. វាមិនមានភាពប្រទូស្តរ៉ាយឡើយដែលថា នៅមានបុគ្គលជាន់ខ្ពស់ជាច្រើនដែលធ្លាប់ពាក់ព័ន្ធនៅក្នុងផែនការរួមដើម្បីកាន់កាប់អំណាចនៅកម្ពុជាក្នុងឆ្នាំ ១៩៧៥ [82]។ ក.ស.ព បានថ្លែងថា ផែនការឧក្រិដ្ឋកម្មរួមត្រូវបានប្រព្រឹត្តឡើងដោយ "ឃាតកម្ម ការធ្វើទារុណកម្ម ការជម្លៀសដោយបង្ខំ ការឃុំឃាំងដោយខុសច្បាប់ ការបង្ខំអោយធ្វើពលកម្ម ព្រមទាំងការធ្វើទុក្ខបុកម្នេញលើសាសនា នយោបាយ និងជនជាតិភាគតិច" [83]។ ដូចដែលបានកត់សំគាល់ដោយ ក.ស.ព នៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ខ្លួនថា "មូលហេតុដែលអះអាងអំពីផែនការឧក្រិដ្ឋកម្មរួមនេះ គឺបានធ្វើអោយមានការផ្លាស់ប្តូរទាំងស្រុងនូវសង្គមកម្ពុជាអោយទៅតាមខ្សែបន្ទាត់មនោគមវិជ្ជា។ ពួកជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម និងគោលនយោបាយ រួមទាំងអ្នកដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ[84]"។

32. ផ្អែកលើការអនុវត្តការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃសហឧក្រិដ្ឋកម្មរួម (JCE) ជនទាំងឡាយដែលអនុវត្ត ឬប្រើប្រាស់ឥទ្ធិពលក្នុងអំឡុងពេលដែលពាក់ព័ន្ធ (ឧទាហរណ៍ ពីរយៈពេលរហូតមកដល់ថ្ងៃទី ១៧ មេសា ១៩៧៥ នៅពេលដែលផែនការឧក្រិដ្ឋកម្មរួម/សហឧក្រិដ្ឋកម្មរួម (JCE) ដែលគេចោទប្រកាន់ត្រូវបានបង្កើតឡើង និងក្រោយមកវាត្រូវបានគេអនុវត្តរហូតដល់ថ្ងៃទី ៦ មករា ១៩៧៩) អាចនឹងត្រូវគេមើលឃើញថាជាសហចារីដែលគេមិនទាន់ត្រូវគេចោទប្រកាន់។ ហេតុដូច្នេះ វាអាចត្រូវបានគេទាញហេតុផល ដូចជាធម្មតាត្រូវបានគេធ្វើក្នុងករណីដែលសហឧក្រិដ្ឋកម្មរួម (JCE) ត្រូវបានគេអនុវត្ត ថាទង្វើរទាំងឡាយដែលធ្វើឡើងដោយបុគ្គលទាំងនេះ គឺជា "ទង្វើរដែលក្នុងវិធីតែមួយមានគោលដៅដើម្បីអោយមានការប្រព្រឹត្តទៅតាមផែនការ ឬគោលបំណងឧក្រិដ្ឋកម្មរួម" [85]។

---

82 សន្មតថា ទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់សហឧក្រិដ្ឋកម្មរួម (JCE) ហួរចូលមកស្នូរ្បីតែគោលដៅនៃសហឧក្រិដ្ឋកម្មរួម (JCE) មិនមែនជាបទល្មើសព្រហ្មទណ្ឌក៏ដោយ៖ "គោលបំណងឧក្រិដ្ឋដែលចែងក្នុងសហឧក្រិដ្ឋកម្មរួម (JCE) អាចបណ្តាលមិនត្រឹមតែមកពីគោលដៅរបស់វាទាំងស្រុងនោះទេ ប៉ុន្តែក៏បណ្តាលមកពីមធ្យោបាយដែលបានរិះគិតដើម្បីសំរេចបាននូវគោលដៅនោះ" រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* *Brima et al.*, SCSL-04-16-A សាលដីកាឧទ្ធរណ៍ ចុះថ្ងៃទី ២២ កុម្ភៈ ២00៨ កថាខណ្ឌ ៧៦ ។

83 "សហព្រះរាជអាជ្ញាបានកំណត់ និងស្នើបញ្ជូនសំរាប់ធ្វើការស៊ើបសួរអំពីអង្គហេតុខុសៗគ្នាចំនួន ២៥ ស្ថានភាពដែលមានជាអាទិ៍៖ ឃាតកម្ម ការធ្វើទារុណកម្ម ការជម្លៀសដោយបង្ខំ ការឃុំឃាំងដោយខុសច្បាប់ ការបង្ខំអោយធ្វើពលកម្ម ព្រមទាំងការធ្វើទុក្ខបុកម្នេញលើសាសនា នយោបាយ និងជនជាតិភាគតិច ដែលជាភស្តុតាងនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងការអនុវត្តន៍ផែនការឧក្រិដ្ឋកម្មរួមនោះ"។

84 *ដដែល* (*Id.*)

85 *សាលដីកាតុលាការកំពូលក្នុងរឿងក្តី* Tadić *កថាខណ្ឌ ២២៨* ។

33. មេធាវីការពារប្រើប្រាស់នូវឧទាហរណ៍ទាំងនេះមិនមែនដើម្បីទាញហេតុផលថា បុគ្គលទាំងឡាយដែលបានវាយនាមតាំងពីដំបូងដែរនៅក្នុងពាក្យសុំនេះ ដោយជាក់លាក់ ឬមិនជាក់លាក់ ប្រឈមមុខនឹង ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។ ផ្ទុយពីនេះទៅវិញបន្តិច គ្មាននរណាម្នាក់ក្នុងចំណោមអ្នកទាំងនោះ គួរត្រូវបានប្រឡាក់ប្រឡូសមិនចាំបាច់ ដោយឧក្រិដ្ឋកម្មណាមួយដែលត្រូវចោទប្រកាន់ដោយ ក.ស.ព នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ទោះបីទំនងជាត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលវាអាចនឹងមានករណីនេះកើតឡើងបើសិនជា សហឧក្រិដ្ឋកម្មរួម (JCE) ត្រូវបានគេអនុវត្ត។

អាស្រ័យដោយមូលហេតុដូចបានលើកឡើងនៅទីនេះ មេធាវីការពារសូមស្នើសុំដោយក្តីគោរពដល់ចៅក្រមជាទីគោរព ដើម្បី ប្រកាសថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់សហឧក្រិដ្ឋកម្មរួម (JCE) មិនមែនទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ឡើយ។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី